**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**

**CAMBODIAN WATER SUPPLY ASSOCIATION**

# របាយការណ៍ប្រចាំឆ្នាំ២០២៣

# ANNUAL REPORT 2023



# មាតិកា


១. អំពីសមាគម ..................................................... ១

១.១ សេចក្តីផ្តើម..................................................... ១

១.២ ទស្សនវិស័យ និងបេសកកម្ម ..................................................... ១

១.៣ ផែនការយុទ្ធសាស្ត្រ ..................................................... ២

២. អភិបាលកិច្ច ..................................................... ២

២.១ សន្និបាតប្រចាំឆ្នាំ២០២២ ..................................................... ២

២.២ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ..................................................... ៣

២.២.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ..................................................... ៣

២.២.២ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល ..................................................... ៣

២.២.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២២..................................................... ៥

៣. ការងារជាមួយសមាជិក ..................................................... ៥

៣.១ អំពីសមាជិកភាព ..................................................... ៥

៣.២ កិច្ចប្រជុំថ្នាក់តំបន់..................................................... ៦

៣.៣ កិច្ចគាំពារសមាជិក..................................................... ៧

៣.៤ ការគាំទ្រជំនួយបច្ចេកទេស ..................................................... ១១

៤. ភាពជាតំណាងឱ្យសមាជិក ..................................................... ១១

៤.១ កិច្ចសហការថ្នាក់ជាតិ..................................................... ១១

៤.១.១ ការចូលរួមសន្និបាតប្រចាំឆ្នាំ២០២២ របស់ក្រសួង ឧរបន ..................................................... ១១

៤.១.២ ការកសាងទំនាក់ទំនងជាមួយក្រសួង ឧរបន..................................................... ១២

៤.១.៣ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាត ..................................................... ១២

៤.២. កិច្ចសហការអន្តរជាតិ..................................................... ១៣

៤.២.១ វគ្គបណ្តុះបណ្តាលស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅប្រទេសជប៉ុន..................................................... ១៣

៤.២.២ សិក្ខាសាលាស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន» ..................................................... ១៣

៤.២.៣ ការសម្របសម្រួលទស្សនកិច្ចសិក្សារបស់គណៈប្រតិភូប្រទេសអាល្លឺម៉ង់ ..................................................... ១៤

៤.២.៤ សន្និសីទ និងពិព័រណ៍ទឹកអូស្ត្រាលី (Ozwater'23) នៅប្រទេសអូស្ត្រាលី ........................ ១៥
៤.២.៥ វេទិកាស្តីពី «ទឹកស្អាត និងទឹកកខ្វក់នៅក្នុងប្រទេសឥណ្ឌូនេស៊ី» .................................. ១៦
៤.២.៦ វេទិកាទឹក លើកទី៥ និងសន្និសីទថ្នាក់តំបន់ ស្តីពីការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់ នៅប្រទេសថៃ ........................................................................................................ ១៦
៤.២.៧ ការចូលរួមសន្និសីទទឹកវៀតណាម (Vietnam Water Week 2023)................................ ១៧
៤.២.៨ ការចូលរួមសន្និសីទ និងពិព័រណ៍ទឹកវៀតណាម "Viet Water 2023" ............................. ១៨
៥. កម្មវិធីកសាងសមត្ថភាពសមាជិក ........................................................................... ១៩
៥.១ វគ្គបណ្តុះបណ្តាល ................................................................................................ ១៩
៦. ភាពជាដៃគូ........................................................................................................ ២០
៦.១ អនុស្សរណៈនៃការយោគយល់គ្នាជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ......................................២០
៦.២ អនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា.......................................២០
៧ . ការផ្តល់សេវាកម្មផ្សេងៗ .........................................................................................២១
៧.១ គូសផែនទីបណ្តាញជូនសមាជិក ...............................................................................២១
៧.២. ផ្តល់សេវាសម្របសម្រួលការងារទឹកស្អាត ....................................................................២១
៧.២.១ ក្រុមហ៊ុន HITACHI ZOSEN CORPORATION ..........................................................២១
៧.២.២ ក្រុមហ៊ុន ធីស៊ីយូ (T.C.U Polys Enterprise Co., Ltd) ..............................................២២
៧.២.៣ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើការលក់ទឹកដុំ (Bulk Water_CAPRED)......................២២
៨. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍.......................................................................... ២៣
៨.១ គម្រោងពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត (WaterAid) ........................................................................................................ ២៣
៨.១.១. ការឧបត្ថម្ភធនលើការភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ...................................... ២៣
៨.១.២ ការប្រមូលទិន្នន័យចុងគ្រា ...................................................................................... ២៣
៨.២ គម្រោងបង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្ទើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន (WaterAid) ........................................................................................................ ២៣
៨.២.១ កិច្ចប្រជុំផ្សព្វផ្សាយ............................................................................................. ២៣

៨.២.២ វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ........................................................................................២៤
៨.២.៣ ការគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ ..................................២៤
៨.៣. គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា (WaterAid)២៥
៨.៣.១ កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត......................................២៥
៨.៣.២ ប្រជុំឆ្លុះបញ្ចាំងលទ្ធផលការអនុវត្តគណនេយ្យភាព វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ....២៦
៨.៤ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់រកទុនកម្ចី (Water.org)............២៦
៨.៤.១ វគ្គបណ្តុះបណ្តាល..........................................................................................................២៦
៨.៥ គម្រោងកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត (Water.org) ........................................................................ ២៧
៨.៥.១ ការចុះកិច្ចព្រមព្រៀង ................................................................................................ ២៧
៨.៥.២ ការសម្របសម្រួលទស្សនកិច្ចសិក្សា............................................................................ ២៧
៨.៥.៣ សិក្ខាសាលាផ្សព្វផ្សាយគម្រោង................................................................................. ២៧
៨.៥.៤ វគ្គបណ្តុះបណ្តាល..........................................................................................................២៨
៨.៥.៥ សិក្ខាសាលាផ្សព្វផ្សាយ«ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត»..................................................៣០
៨.៥.៦ ទស្សនកិច្ចសិក្សា............................................................................................................៣១
៨.៥.៧ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និង ស្ថាប័នហិរញ្ញវត្ថុ.... ៣២
៨.៥.៨ ការឧបត្ថម្ភធនលើឧបករណ៍តេស្តគុណភាពទឹកស្អាត ................................................ ៣៣
៨.៥.៩ កិច្ចប្រជុំជាមួយ អគ្គនាយកដ្ឋានទឹកស្អាត.................................................................... ៣៣
៨.៥.១០ ការផលិតវីដេអូអប់រំ ..................................................................................................៣៤
៨.៦ គម្រោងសម្ពន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED_AEA).........................................................................................................................៣៤
៨.៦.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង ....................................................................................៣៤
៨.៦.២ សិក្សាលម្អិតលើការពង្រីកបណ្តាញបំពង់ទឹកស្អាត..........................................................៣៥
៨.៦.៣ ការដេញថ្លៃបំពង់ទឹកស្អាត ............................................................................................៣៥
៨.៦.៤ វគ្គបណ្តុះបណ្តាល..........................................................................................................៣៦

៨.៦.៥ សិក្ខាសាលាផ្សព្វផ្សាយ «ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងកិច្ចប្រជុំបច្ចេកទេសទឹកស្អាត» ..... ៣៧

៨.៦.៦ សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង ..... ៣៨

៨.៦.៧ ការបោះពុម្ពសម្ភារៈផ្សព្វផ្សាយ ..... ៣៩

៨.៧ គម្រោងសហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន (EMW) ..... ៣៩

៨.៧.១ ការតេស្តសាកល្បងប្រើប្រាស់សម្ភារៈផ្សព្វផ្សាយ ..... ៣៩

៨.៧.២ វគ្គបណ្តុះបណ្តាល ..... ៣៩

៨.៧.៣ សិក្ខាសាលា ..... ៤០

៨.៨ គម្រោង «ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា» (UTS) ..... ៤១

៨.៨.១ វគ្គបណ្តុះបណ្តាល ..... ៤១

៩. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ..... ៤២

១០. បញ្ហាប្រឈម ..... ៤៣

១០.១ បញ្ហាប្រឈមរបស់វិស័យទឹកស្អាត ..... ៤៣

១០.២ បញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ..... ៤៣

១០.៣ បញ្ហាប្រឈមរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ..... ៤៤

១១. សមាសភាពក្រុមប្រឹក្សាភិបាលសមាគម និងបុគ្គលិក ..... ៤៤

១១.១. ក្រុមប្រឹក្សាភិបាលសមាគម ..... ៤៤

១១.២. បុគ្គលិកសមាគម ..... ៤៩

# របាយការណ៍បូកសរុបលទ្ធផលការងារសមាគមប្រចាំឆ្នាំ២០២៣ និងទិសដៅការងារសម្រាប់ឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៣ សមាគមបានអនុវត្តតាមផែនការណ៍យុទ្ធសាស្រ្ត ២០២០-២០២៤ និងបានសហការជាមួយក្រសួង ឧរ៉បន ពិសេសអគ្គនាយកដ្ឋានទឹកស្អាត ក៏ដូចជាដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រដល់ការងាររបស់សមាគម។ ជាលទ្ធផល សមាគមបានរៀបចំសន្និបាតប្រចាំឆ្នាំ២០២២ ប្រកបដោយជោគជ័យ ដែលមានសមាជិកចូលរួម ៣០៦ នាក់(ស្រី ៦៥នាក់) និងបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ ១)សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដើម្បីអត្ថប្រយោជន៍របស់សមាជិក ២)វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ICT) លើកម្មវិធីសិក្សាបរិញ្ញាបត្ររងវិស្វកម្មផ្គត់ផ្គង់ទឹកស្អាត និងប្រព័ន្ធទឹកក្នុងអគារ ដើម្បីបង្កើនធនធានមនុស្សលើវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។

សមាគមបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលចំនួន ៩លើក ដើម្បីពិនិត្យមើលការងារប្រតិបត្តិរបស់សមាគម និងលើកផែនការត្រីមាសបន្តបន្ទាប់។ កិច្ចប្រជុំនេះបានពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមាជិកដែលបាននឹងកំពុងជួបប្រទះ។ ជាលទ្ធផល សមាគមបានដោះស្រាយបញ្ហាជូនសមាជិកបាន ១០ករណី។ សមាគមក៏បានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ ៣លើក ដើម្បីស្តាប់សំឡេងសមាជិក ចែករំលែកបទពិសោធន៍ និងបច្ចេកវិទ្យាថ្មីៗ ក៏ដូចជាការរឹតចំណងទំនាក់ទំនងឱ្យកាន់តែប្រសើរ។

សមាគមក៏បានចូលរួមសន្និបាតប្រចាំឆ្នាំរបស់ក្រសួង ឧរ៉បន និងបានដឹកនាំសមាជិកចូលរួមសិក្ខាសាលាស្តីពី «ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន» និងបានរៀបចំទស្សនកិច្ចសិក្សាជូនគណៈប្រតិភូអាល្លឺម៉ង់ ដើម្បីស្វែងយល់ពីប្រព័ន្ធទឹកស្អាត និងទឹកកខ្វក់នៅកម្ពុជា។ សមាគមបានដឹកនាំសមាជិកចូលរួម ១)វគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជប៉ុន ២)សន្និសីទ និងពិព័រណ៍ទឹកអូស្រ្តាលី (Ozwater’23) ៣)វេទិកាទឹកលើកទី៥ និងសន្និសីទថ្នាក់តំបន់ស្តីពីការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់ នៅប្រទេសថៃ ៤)ការចូលរួមសន្និសីទ និងពិព័រណ៍ទឹកវៀតណាម(Viet Water)។ លើសពីនេះទៅទៀតសមាគមក៏បានចូលរួមវេទិកា «ទឹកស្អាត និងទឹកកខ្វក់នៅប្រទេសឥណ្ឌូនេស៊ី» និងការចូលរួមសន្និសីទទឹកវៀតណាម (Vietnam Water Week) ផងដែរ។

ក្នុងឆ្នាំ២០២៣ សមាគមបានអនុវត្តគម្រោងជាមួយអង្គការដៃគូរួមមាន៖ អង្គការ WaterAid, Water.org, Aide et Action(AEA)_CO-SAVED, East Meets West (EMW) និង University of Technology Sydney (UTS) ដើម្បីជួយគាំទ្រទៅដល់សមាជិក។ ជាងនេះទៅទៀត សមាគមបានផ្តល់សេវាកម្មសម្របសម្រួល ១)ការងារទឹកស្អាតជូនក្រុមហ៊ុន HITACHI ZOSEN CORPORATION ២)គូសផែនទីបណ្តាញពំពង់ទឹកស្អាតជូនសមាជិក ៣)អញ្ជើញសមាជិកទៅចូលរួមខួប ៧ឆ្នាំរបស់ក្រុមហ៊ុន TCU Poly Enterprise Co., LTD ៤)សម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់លក់ទឹកបោះដុំ (Bulk Water)_CAPRED។

ម្យ៉ាងវិញទៀតសមាគមបានរៀបចំដំឡើងប្រព័ន្ធគ្រប់គ្រងគណនេយ្យថ្មី គោលការណ៍គណនេយ្យសម្រាប់កម្មវិធី QuickBooks ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ២០២២ និង២០២៣ និងប្រើប្រាស់ប្រព័ន្ធអ៊ីធឺណែតប៊ែងឃីង (Internet Banking) សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុសមាគមតាមរយៈធនាគារ។

សម្រាប់ឆ្នាំ២០២៤ សមាគមនៅតែបន្តអនុវត្តផែនការយុទ្ធសាស្រ្ត ២០២០ - ២០២៤ ដោយផ្តោតទៅលើ ១)ការកសាងសមត្ថភាពជូនសមាជិក ២)ការរៀបចំព្រឹត្តិការណ៍ សន្និបាត សន្និសីទនិងពិព័រណ៍ទឹកកម្ពុជាលើកទី៥ កិច្ចប្រជុំថ្នាក់តំបន់ ៣)ផ្តល់សេវាកម្មជូនសមាជិក និងអង្គការដៃគូ ៤)បង្កើនកិច្ចសហការដៃគូជាតិ និងអន្តរជាតិលើការងារគម្រោង និងព្រឹត្តិការណ៍នានាទាក់ទងទៅនឹងវិស័យទឹកស្អាត និង ៥)ស្វែងរកមូលនិធិដើម្បីនិរន្តរភាពសមាគម។

# ១. អំពីសមាគម

## ១.១ សេចក្ដីផ្ដើម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា( ស.ទ.ក ) ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្ដល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណ ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី( MSME)នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃតាមសេចក្ដីជូនដំណឹងលេខៈ ១០៧៧ សជណ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្ដីប្រកាសលេខៈ ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល មានអាសយដ្ឋាននៃទីស្នាក់ការកណ្ដាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្ដុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

ក្នុងឆ្នាំ២០២៣ សមាគមមានសមាសភាពក្រុមប្រឹក្សាភិបាលចំនួន ៩រូប (ស្រី ១រូប) ដែលមានរចនាសម្ព័ន្ធៈ ប្រធាន ១រូប អនុប្រធាន ១រូប ហេរញ្ញិក ១រូប និងសមាជិកចំនួន ៦រូប។ សមាគមមានបុគ្គលិកសរុបចំនួន ៩រូប (ស្រី ៤រូប) និងមានសមាជិកសរុបចំនួន ៣៤៣ស្ថានីយ/ក្រុមហ៊ុន ដែលក្នុងនោះមាន ៣០០ស្ថានីយ បាននឹងកំពុងប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

## ១.២ ទស្សនវិស័យ និងបេសកកម្ម

### ១.២.១ ទស្សនវិស័យ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា គឺចង់ឃើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានសេវាទឹកស្អាត និងអនាម័យដែលមានគុណភាពស្របតាមស្តង់ដាថ្នាក់ជាតិ។

### ១.២.២ បេសកកម្ម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានបេសកកម្មដូចខាងក្រោម៖

- គាំទ្រ និងលើកកម្ពស់ការជួយគ្នាទៅវិញទៅមករវាងអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- បង្កើនចំណេះដឹង បច្ចេកទេសស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ និង
- ជំរុញឱ្យមាននិរន្តរភាព និងការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។

## ១.៣ ផែនការយុទ្ធសាស្ត្រ

ក្នុងឆ្នាំ២០២៣ សមាគមបន្តអនុវត្តតាមផែនការយុទ្ធសាស្ត្រ ២០២០ -២០២៤។

- ការពារ និងពង្រឹងសមត្ថភាពសមាជិករបស់ខ្លួន
- ធ្វើឱ្យមាននិរន្តរភាពហិរញ្ញវត្ថុរបស់សមាគម
- ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត។

# ២. អភិបាលកិច្ច

## ២.១ សន្និបាតប្រចាំឆ្នាំ២០២២

សន្និបាតសមាគមលើកទី១១ ប្រចាំឆ្នាំ២០២២ ប្រារព្ធឡើងនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ឧវបន។ សន្និបាតមានការចូលរួមពីក្រសួង ឧវបន ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថានទូតចក្រភពអង់គ្លេស ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន និងសមាជិកសមាគម សរុបចំនួន ៣០៦នាក់(ស្រី ៦៥នាក់)។




*រូបភាពទី ១៖ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួង ឧវបន ថ្លែងសុន្ទរកថាបើកអង្គសន្និបាតលើកទី១១*

សមាគមសូមថ្លែងអំណរគុណជូនចំពោះក្រុមហ៊ុនដែលបានសហការឧបត្ថម្ភសន្និបាតលើកទី១១រួមមាន៖

**សហការឧបត្ថម្ភដោយ** *GOLD SPONSORS*

**ដៃគូសហការ** *PARTNERS*

## ២.២ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

### ២.២.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស

ក្នុងឆ្នាំ២០២៣ សមាគមបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាលបានចំនួន ៣លើក ដោយផ្តោតទៅលើ៖

- ❖ ការរៀបចំសន្និបាតលើកទី១១ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣
- ❖ ការចុះអនុស្សារណៈយោគយល់គ្នារវាង សមាគម CWA និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា CMA
- ❖ ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី«ការគ្រប់គ្រងទឹកស្អាត»នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣
- ❖ សមិទ្ធិផលស្នាដៃសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល អាណត្តិទី៣ និងការរៀបចំព្រាងលិខិតស្នើសុំកិច្ចអន្តរាគមន៍ក្នុងការអនុគ្រោះលើកលែងពន្ធសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។



*រូបភាពទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសទី២ នៅការិយាល័យសមាគម*

### ២.២.២ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២៣ សមាគមបានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលតាមអនឡាញ និងប្រជុំផ្ទាល់ចំនួន ៦លើក ផ្តោតទៅលើ៖

- ❖ ការអញ្ជើញសមាជិកចូលរួមក្នុង «**ទិវាជាតិ វិទ្យាសាស្ត្រ និងនវានុវត្តន៍**» និង «**ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា អន្តរជាតិលើកទី១ ឆ្នាំ២០២៣**» របស់ក្រសួង ឧវបន។
- ❖ ពិនិត្យ និងសិក្សាថ្លៃដើមលក់ទឹកស្អាតឡើងវិញជូនសមាជិក។
- ❖ ពិភាក្សាលើការផ្គត់ផ្គង់ទឹកស្អាតក្រោមគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ ជាលទ្ធផល តំណាង ADB នឹងពិភាក្សាគ្នាបន្ថែមលើ៖ ១)មិនអនុញ្ញាតឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពនៅក្នុងតំបន់ដែលមានអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតឯកជន ២)ក្រុមការងាររបស់ ADB ដែលបានធ្វើការសិក្សាសមិទ្ធិលទ្ធភាពរួចហើយ បើតំបន់នោះមានអាជ្ញាបណ្ណត្រូវបង្វែរចេញហើយនឹងពិចារណាគាំទ្រដល់ប្រតិបត្តិករដែលកំពុងផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់នោះ។
- ❖ ដំណើរទស្សនកិច្ចសិក្សារោងចក្រផលិតបំពង់របស់ក្រុមហ៊ុន LESSO PIPES (CAMBODIA) TRADING CO., Ltd

- ❖ ពិភាក្សាស្វែងរកដំណោះស្រាយបញ្ហាគុណភាពទឹករបស់សមាជិក ដែលមានការចុះផ្សាយលើបណ្តាញសង្គម CTV Online។ កិច្ចប្រជុំនេះក៏បានផ្តល់អនុសាសន៍ និងលើកផែនការដែលនឹងត្រូវអនុវត្តបន្តសម្រាប់រយៈពេលមធ្យម(៦ខែ ទៅ១ឆ្នាំ) និងរយៈពេលវែង(១ឆ្នាំ ទៅ៣ឆ្នាំ)ជូនសមាជិក។
- ❖ ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ ការជ្រើសរើសសវនកម្មខាងក្រៅ (External Auditor Firm) និងដោះស្រាយបញ្ហាសមាជិកដែលមិនទាន់បានបង់ប្រាក់ភាគទានសមាជិកភាពចាប់តាំងពីឆ្នាំ២០២១។
- ❖ ដំណើរការនៃការដាក់លិខិតស្នើសុំកិច្ចអន្តរាគមន៍ក្នុងការអនុគ្រោះលើកលែងពន្ធសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ការរៀបចំសន្និបាតប្រចាំឆ្នាំលើកទី១២ និងការផ្តល់សេវាកម្មអញ្ជើញសមាជិកចូលរួមខួប ៧ឆ្នាំរបស់ក្រុមហ៊ុនជីស៊ីយូ ប៉ូលីអេធើប្រាយ។
- ❖ បន្តពិភាក្សាលើការរៀបចំសន្និបាតលើកទី១២ របាយការណ៍សវនកម្ម(Audit 2021 & 2022) និងពិនិត្យសម្រេចលើលិខិតជ្រើសរើសក្រុមប្រឹក្សាភិបាលសមាគម សម្រាប់អាណត្តិទី៤។



*រូបភាពទី៣៖ កិច្ចប្រជុំពិភាក្សាករណីគុណភាពទឹក នៅការិយាល័យសមាគម*



*រូបភាពទី៤៖ កិច្ចប្រជុំជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) នៅការិយាល័យសមាគម*

### ២.២.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២២

កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២២ បានប្រារព្ធឡើងចាប់ពីថ្ងៃទី២-៤ ខែកុម្ភៈ ឆ្នាំ២០២៣ នៅខេត្តកំពត ដោយមានការចូលរួមពីបុគ្គលិកចំនួន ៩នាក់ (ស្រី ៤នាក់) និងសមាជិកក្រុមប្រឹក្សាភិបាលសមាគមចំនួន ៦នាក់ សរុបចំនួន ១៥នាក់(ស្រី ៤នាក់) ក្នុងគោលបំណងដើម្បីៈ ១)បង្ហាញលទ្ធផលការងារឆ្នាំ២០២២ ២)ផែនការសកម្មភាពការងារឆ្នាំ២០២៣ ៣)ពិភាក្សាពីរបៀបវារៈសម្រាប់កម្មវិធីសន្និបាត ៤)មតិវាយតម្លៃសមាគម ៥)បទបង្ហាញអំពីគោលការណ៍បុគ្គលិក និង ៦)ការកែប្រែតម្លៃសមាជិកភាព។



*រូបភាពទី៥៖ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២២ នៅសណ្ឋាគារ កំពត ផារ៉េដៃយ*

# ៣. ការងារជាមួយសមាជិក

## ៣.១ អំពីសមាជិកភាព

សមាជិកសមាគមមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងសមាជិកសមាគមកើនដល់ ៣៤៣ស្ថានីយ/ក្រុមហ៊ុន នៅដំណាច់ឆ្នាំ២០២៣ ក្នុងនោះសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៣០០ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាត សរុបចំនួន ៤៣ក្រុមហ៊ុន បាននឹងកំពុងប្រតិបត្តិការក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកសម្រាប់ឆ្នាំ២០២៣ មានសមាជិកចូលថ្មីមានចំនួន ២៩ស្ថានីយ/ក្រុមហ៊ុន ដែលក្នុងនោះមានសមាជិកអាជីពចំនួន ១៨ស្ថានីយ និងសមាជិកគាំទ្រចំនួន ១១ក្រុមហ៊ុន។ ហើយសមាជិកឈប់អស់ ៥ស្ថានីយ (២ស្ថានីយប្តូរម្ចាស់ហើយចូលជាសមាជិកថ្មី) និងសមាជិកគាំទ្រឈប់ចំនួន ៣ក្រុមហ៊ុន។




*ក្រាហ្វិច១៖ ទិន្នន័យសមាជិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

## ៣.២ កិច្ចប្រជុំថ្នាក់តំបន់

ក្នុងឆ្នាំ២០២៣ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់បានចំនួន ៣លើក ក្នុងគោលបំណងដើម្បី៖១)បង្កើនទំនាក់ទំនងរវាងសមាជិក និងថ្នាក់ដឹកនាំសមាគម ក៏ដូចជារវាងសមាជិកនិងសមាជិក ២)ស្វែងយល់ពីការរីកចម្រើនបញ្ហាប្រឈម និងបង្កើតផែនការសកម្មភាពដើម្បីរកដំណោះស្រាយជូនសមាជិក ៣)បច្ចុប្បន្នភាពអំពីច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និង ៤)ចែករំលែកចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។

- **លើកទី១៖** ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅសណ្ឋាគារ និងភោជនីយដ្ឋានភ្នំប្រុស ខេត្តកំពង់ចាម មានអ្នកចូលរួមសរុបចំនួន ៥៤នាក់(ស្រី ១៣នាក់) អញ្ជើញមកពីតំណាងមន្ទីរ ឧរបន ខេត្តកំពង់ចាម ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ចំនួន ៣៨ស្ថានីយ មកពីខេត្តកំពង់ចាម កំពង់ធំ ត្បូងឃ្មុំ ក្រចេះ និងព្រៃវែង។ កម្មវិធីនេះឧបត្ថម្ភដោយ ក្រុមហ៊ុន LESSO Cambodia។
- **លើកទី២៖** ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅសណ្ឋាគារផាមរីវើ ខេត្តកំពង់ស្ពឺ ទទួលបានការឧបត្ថម្ភពីក្រុមហ៊ុនធីស៊ីយូប៉ូលីអេធើប្រាយ ក្រុមហ៊ុនភ្នំពេញប្លាស្ទិចប្រូដាក់ និងក្រុមហ៊ុនដៃគូទឹកកម្ពុជា។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួ ៥៤នាក់(ស្រី ៩នាក់) អញ្ជើញមកពីប្រធានមន្ទីរ ឧរបន ខេត្តកំពង់ស្ពឺ និងសហការីក្រុមប្រឹក្សាភិបាលនិងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២ស្ថានីយ មកពីខេត្តកំពង់ស្ពឺ តាកែវ កំពត និងខេត្តព្រះសីហនុ។
- **លើកទី៣៖** ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារក្លាស់ស៊ី ខេត្តបាត់ដំបង ទទួលបានការឧបត្ថម្ភពីក្រុមហ៊ុនធីស៊ីយូប៉ូលីអេធើប្រាយ ក្រុមហ៊ុនដៃគូទឹកកម្ពុជា និងធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ម.ក (SME Bank)។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៧៤នាក់(ស្រី ១១នាក់)អញ្ជើញមកពី អនុប្រធានមន្ទីរ ឧរបន ខេត្តបាត់ដំបងនិងសហការី ក្រុមប្រឹក្សាភិបាលនិងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន ធនាគារ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣៥ស្ថានីយ មកពីខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង។



*រូបភាពទី៦៖ កិច្ចប្រជុំថ្នាក់តំបន់ដែលរៀបចំឡើងនៅខេត្តបាត់ដំបង*

## ៣.៣ កិច្ចគាំពារសមាជិក

សមាគមបានគាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយបញ្ហារបស់សមាជិកបានចំនួន ១០ករណីរួមមាន៖

១. ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ សមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល បានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត ដែលដឹកនាំដោយ **លោក ហ៊ុយ រិទ្ធី** អគ្គនាយករង អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និងមន្ត្រីមន្ទីរ ឧរបន ខេត្តពោធិ៍សាត់ បានរៀបចំកិច្ចប្រជុំដោះស្រាយវិវាទរបស់ប្រតិបត្តិករជាសមាជិករបស់សមាគមទាក់ទងទៅនឹងតំបន់អាជ្ញាបណ្ណ។




*រូបភាពទី៧៖ កិច្ចប្រជុំដោះស្រាយទំនាស់*

២. ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ សមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល សមាគម បានសហការជាមួយ អគ្គនាយកដ្ឋានទឹកស្អាត ដឹកនាំដោយ **លោក ហ៊ុយ រិទ្ធី** អគ្គនាយករង អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និងលោកអនុប្រធានមន្ទីរ ឧរបន ខេត្តបាត់ដំបង និងសហការីបានរៀបចំកិច្ចប្រជុំដោះស្រាយវិវាទរបស់ប្រតិបត្តិករជាសមាជិកទាក់ទងទៅនឹងតំបន់អាជ្ញាបណ្ណ។



*រូបភាពទី៨៖ កិច្ចប្រជុំសម្របសម្រួល*

៣. ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ សមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល សមាគម បានសហការជាមួយ អគ្គនាយកដ្ឋានទឹកស្អាត ដឹកនាំដោយ **លោក ហ៊ុយ រិទ្ធី** អគ្គនាយករង អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានទឹកស្អាត និងលោកអនុប្រធានមន្ទីរ ឧរបន ខេត្តបន្ទាយមានជ័យ និងសហការី បានរៀបចំកិច្ចប្រជុំដោះស្រាយវិវាទរបស់ប្រតិបត្តិករជាសមាជិកទាក់ទងទៅនឹងតំបន់អាជ្ញាបណ្ណ។




*រូបភាពទី៩៖ កិច្ចប្រជុំសម្របសម្រួលនៅសាលាឃុំបន្ទាយនាង*

៤. ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ សមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម បានសហការជាមួយ រដ្ឋបាលខេត្តកំពង់ស្ពឺ ដឹកនាំដោយ **ឯកឧត្តម ស្រ៊ុន ស្រ៊ន់** អភិបាលរងខេត្តកំពង់ស្ពឺ និងមានការចូលរួមពីមន្ទីរ ឧរបន មន្ទីរអភិវឌ្ឍន៍ជនបទ ប្រតិបត្តិករ និងតំណាងទឹកសហគមន៍ ដើម្បីដោះស្រាយវិវាទរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងទឹកសហគមន៍កសិកម្ម។



*រូបភាពទី១០៖ កិច្ចប្រជុំដោះស្រាយទំនាស់រវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងទឹកសហគមន៍កសិកម្ម*

៥. សមាគមបានពិគ្រោះយោបល់ និងសម្របសម្រួលជួយសមាជិកជាប្រតិបត្តិករ ក្នុងការចុះសិក្សាថ្លៃដើម និងរៀបចំលិខិតឆ្លើយតបជូនទៅគណៈកម្មការវាយតម្លៃថ្លៃទឹករបស់ក្រសួង ឧវបន ដើម្បីសុំឱ្យគណៈកម្មការពិនិត្យ និងវាយតម្លៃឡើងវិញ។

៦. ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ សមាគមបានសហការជាមួយ មន្ទីរ ឧវបន ខេត្តតាកែវ ចុះសួរសុខទុក្ខ និងសួរនាំពីបញ្ហាគុណភាពប្រភពទឹក និងគុណភាពទឹកស្អាត ដែលមានការចុះផ្សព្វផ្សាយលើបណ្តាញសង្គមរបស់ CTV online។ ក្រោយពីពិនិត្យមើលស្ថានភាពជាក់ស្តែង ក្រុមការងារបានផ្តល់អនុសាសន៍ និងរៀបចំផែនការកែលម្អគុណភាពទឹកស្អាតជូនប្រតិបត្តិករ។



*រូបភាពទី១១៖ ប្រភពទឹកឆៅ*

៧. ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ សមាគមចូលរួមក្នុងកិច្ចប្រជុំជាមួយមន្ទីរ ឧវបន ខេត្តតាកែវ សមាគមអភិវឌ្ឍន៍វិជ្ជាពេទ្យបារាំង និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ជាសមាជិក រកដំណោះស្រាយ ដើម្បីភាគីទាំងពីរអាចទទួលយកបាន។

៨. ថ្ងៃទី១២ និង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ សមាគមបានសហការជាមួយមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ បានជួបប្រជុំជាមួយអាជ្ញាធរឃុំព្រៃវិហារ មេភូមិ អ្នកតំណាងភូមិដំរីស្លាប់ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតជាសមាជិក ដើម្បីដោះស្រាយបញ្ហាកង្វះខាតប្រភពទឹក។



*រូបភាពទី១២៖ លោកមេឃុំស្ដីទីនៃឃុំព្រៃវិហារពន្យល់ប្រជាពលរដ្ឋពីផលប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត*

៩. ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ សមាគមបានសហការជាមួយ មន្ទីរ ឧវបន ខេត្តតាកែវ បានជួបប្រជុំជាមួយ លោកអភិបាលស្រុកគីរីវង់ ខេត្តតាកែវ ដើម្បីដោះស្រាយវិវាទរវាង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ជាសមាជិក ជាមួយទឹកសហគមន៍ និងអ្នកលក់ទឹកផៅ។ ជាលទ្ធផល លោកអភិបាលស្រុកគីរីវង់នឹងពិនិត្យមើលពាក្យបណ្ដឹងរបស់ប្រតិបត្តិករ ដើម្បីធ្វើការដោះស្រាយ។



*រូបភាពទី១៣៖ អណ្តូងដែលជាប្រភពទឹករបស់អាជីវករប្រកបមុខរបរលក់ទឹកផៅ*



*រូបភាពទី១៤៖ ម៉ូទ័របូមទឹកអណ្តូងរបស់សហគមន៍សម្រាប់ធ្វើការចែកចាយទឹកទៅដល់អ្នកប្រើប្រាស់*

១០. សមាគមសហការជាមួយ មន្ទីរ ឧវបន ខេត្តតាកែវ ក្នុងការជួយដល់ប្រតិបត្តិករ ដើម្បីប្រមូលព័ត៌មាន និងរៀបចំឯកសារគាំទ្រផ្សេងៗក្នុងគោលបំណងរៀបចំលិខិត«**សំណើសុំពិនិត្យ និងសម្រេចឡើងវិញលើសំណើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត**» ដាក់ជូន **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួង ឧវបន។

## ៣.៤ ការគាំទ្រជំនួយបច្ចេកទេស

នៅឆ្នាំ២០២៣ បុគ្គលិកបច្ចេកទេសសមាគម បានផ្តល់ជំនួយបច្ចេកទេសក្នុងការធ្វើតេស្តគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ ជូនដល់ប្រតិបត្តិករចំនួន ៤ស្ថានីយ និងការធ្វើជ្យារតេស្តទឹកចៅដើម្បីកំណត់សារធាតុគីមីប្រើប្រាស់ឱ្យបានត្រឹមត្រូវក្នុងការផលិតទឹកស្អាត ជូនប្រតិបត្តិករចំនួន ៦ស្ថានីយ។ ការផ្តល់ជំនួយបច្ចេកទេសទាំងនេះបានរួមចំណែកក្នុងការដោះស្រាយបញ្ហាគុណភាពទឹក និងចំណេញថ្លៃប្រតិបត្តិការ និងការផ្តល់ជាអនុសាសន៍កែលម្អលើការផលិតទឹកប្រកបដោយគុណភាព និងសុវត្ថិភាពដល់អ្នកប្រើប្រាស់។



*រូបភាពទី១៥៖ ការតេស្តគុណភាពទឹកស្អាត និងការធ្វើជ្យារតេស្តទឹកចៅ*

# ៤. ភាពជាតំណាងឱ្យសមាជិក

## ៤.១ កិច្ចសហការថ្នាក់ជាតិ

### ៤.១.១ ការចូលរួមសន្និបាតប្រចាំឆ្នាំ២០២២ របស់ក្រសួង ឧវបន

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានចូលរួមសន្និបាតប្រចាំឆ្នាំ២០២២ របស់ក្រសួង ឧវបន នៅទីស្តីការក្រសួង។ ក្នុងឱកាសនោះដែរ **លោក ហម ងួន** អនុប្រធានសមាគម បានធ្វើបទអន្តរាគមន៍ស្តីពីសមិទ្ធិផលការងារសមាគមឆ្នាំ២០២២ បញ្ហា និងសំណូមពរ សុំឱ្យក្រសួង ឧវបន ជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ការគាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។




*រូបភាពទី១៦៖ ការចូលរួមសន្និបាតប្រចាំឆ្នាំ២០២២ របស់ក្រសួង ឧវបន*

## ៤.១.២ ការកសាងទំនាក់ទំនងជាមួយក្រសួង ឧវបន

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគម បានចូលជួបសម្តែងការគួរសម និងអបអរសាទរ ជូនចំពោះ **ឯកឧត្តម ហែម វណ្ណឌី** ក្នុងឱកាសដ៏ថ្លៃថ្លា ដែលរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងគាំទ្រជា រដ្ឋមន្ត្រីក្រសួង ឧវបន នីតិកាលទី៧ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ កន្លងទៅថ្មីៗនេះ។ ក្នុងជំនួបនេះដែរ **ឯកឧត្តមរដ្ឋមន្ត្រី** បានផ្តល់ជាអនុសាសន៍ណែនាំដ៏ថ្លៃថ្លា ដើម្បីជាចក្ខុវិស័យសម្រាប់សមាគមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងអនុវត្តការងាររបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ។



*រូបភាពទី១៧៖ ការចូលជួបសម្តែងការគួរសម និងអបអរសាទរ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួង ឧវបន*

## ៤.១.៣ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាត

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ សមាគមដឹកនាំដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល បានចូលជួបប្រជុំជាមួយ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត បានពិភាក្សាអំពី៖ ១)សុំអនុគ្រោះសារពើពន្ធរួមមាន៖ ការលើកលែងពន្ធអប្បបរមា ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូល និងពន្ធអាករលើតម្លៃបន្ថែម(VAT) រហូតដល់ឆ្នាំ២០៣០ ២)សុំឱ្យមានសំណងសមរម្យពេលមានការខូចខាតបំពង់ទឹកស្អាត និង ៣)សុំជួយឧបត្ថម្ភធន និងទុនវិនិយោគសម្រាប់ទឹកស្អាតឯកជន។



*រូបភាពទី១៨៖ កិច្ចប្រជុំជាមួយ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត*

## ៤.២. កិច្ចសហការអន្តរជាតិ

### ៤.២.១ វគ្គបណ្តុះបណ្តាលស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅប្រទេសជប៉ុន

ថ្ងៃទី៩-១១ ខែមករា ឆ្នាំ២០២៣ សមាគមបានដឹកនាំក្រុមការងារ និងសមាជិកសរុបចំនួន ១០នាក់ រួមមានៈ ប្រធានសមាគម និងបុគ្គលិក ៣នាក់ និងប្រតិបត្តិករដឹកនាំជាស្ត្រីចំនួន ៦នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី **«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត»** នៅក្រុងគីតាយូស៊ូ ក្រុងណាគូយ៉ា និងទីក្រុងតូក្យូ ប្រទេសជប៉ុន ក្រោមការគាំទ្រឧបត្ថម្ភពី ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃរាជរដ្ឋាភិបាលជប៉ុន តាមរយៈកិច្ចសហការ និងសម្របសម្រួល ដោយ សមាគមសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្រៅប្រទេស និងភាពជាដៃគូប្រកបដោយនិរន្តរភាព (AOTS) និង សមាគមអាជីវកម្មទឹកស្អាតក្រៅប្រទេស ក្រុងគីតាយូស៊ុ (KOWBA)។



*រូបភាពទី១៩៖ ការថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំនៃរដ្ឋាករទឹកស្អាត និងប្រព័ន្ធអនាម័យ ក្រុង KITAKYUSHU*

### ៤.២.២ សិក្ខាសាលាស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន»

ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងសមាជិកសមាគមចំនួន ២៣ស្ថានីយ បានចូលរួមសិក្ខាសាលា«**ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន**» លើកទី១៥ ស្តីពី«**សេចក្តីព្រាងច្បាប់ ការគ្រប់គ្រងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា**»។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពង់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួង ឧវបន។ សិក្ខាសាលាមានចំនួនអ្នកចូលរួមប្រមាណ ១៦០នាក់។




*រូបភាពទី ២០៖ រូបថតអនុស្សាវរីយ៍ក្នុងសិក្ខាសាលា*

## ៤.២.៣ ការសម្របសម្រួលទស្សនកិច្ចសិក្សារបស់គណៈប្រតិភូប្រទេសអាល្លឺម៉ង់

ថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ សមាគមបានសម្របសម្រួលដឹកនាំគណៈប្រតិភូអាល្លឺម៉ង់ ដែលអញ្ជើញមកធ្វើទស្សនកិច្ចសិក្សាពីប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់ នៅកម្ពុជា។ ជាលទ្ធផល ក្រុមការងារបាន សម្របសម្រួលសកម្មភាពមួយចំនួនខាងក្រោម៖



*រូបភាពទី ២១៖ ការថតរូបអនុស្សាវរីយ៍ របស់គណប្រតិភូអាល្លឺម៉ង់ក្រោយបញ្ចប់ការសម្តែងការគួរសម*

១. ជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំក្រសួង ឧវបន ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួង ឧវបន។

២. ជួបប្រជុំជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីស្វែងយល់ពីប្រវត្តិ ដំណើរការផលិត និងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ព្រមទាំងធ្វើទស្សនកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតភូមិព្រែក ដើម្បីស្វែងយល់អំពីចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ជាមួយគ្នានេះសមាគមសូមថ្លែងអំណរគុណ **លោក ម៉ា ណូរ៉ាទីន** អគ្គនាយករងនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានទទួលស្វាគមន៍ក្រុមការងារ និងគណៈប្រតិភូយ៉ាងកក់ក្តៅ ព្រមទាំងធ្វើបទបង្ហាញអំពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

៣. រៀបចំសិក្ខាសាលាស្តីពី«ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត និងទឹកកខ្វក់ កម្ពុជា-អាល្លឺម៉ង់» ដែលមានការបង្ហាញអំពីផលិតផល និងសេវាកម្មរបស់ប្រទេសអាល្លឺម៉ង់ជូនប្រតិបត្តិករ។

៤. រៀបចំកិច្ចពិភាក្សាតុមូលដើម្បីស្វែងយល់ពីយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់វិស័យទឹកស្អាត និងទឹកកខ្វក់នៅកម្ពុជា រវាងគណៈប្រតិភូប្រទេសអាល្លឺម៉ង់ និងតំណាងក្រសួង ឧវបន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧត្តុនិយម។ ជាលទ្ធផលគណៈប្រតិភូបានស្វែងយល់អំពីទិដ្ឋភាពទូទៅ គោលការណ៍ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងទាំង៤ សម្រាប់វិស័យទឹកស្អាត និងទឹកកខ្វក់នៅកម្ពុជា។

៥. ទស្សនកិច្ចសិក្សារោងចក្រផលិតដំណាប់ស្វាយនៅគីរីរម្យ ខេត្តកំពង់ស្ពឺ ដើម្បីស្វែងយល់ពីរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់។

៦. ទស្សនកិច្ចសិក្សានៅអង្គភាពរដ្ឋាករទឹកកំពង់ធំ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្រុកសូទ្រនិគម ដើម្បីស្វែងយល់ពីប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត។

៧. ទស្សនកិច្ចសិក្សានៅអង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប និងប្រព័ន្ធសម្អាតទឹកកខ្វក់របស់ក្រុងសៀមរាប។



*រូបភាពទី ២២៖ ទស្សនកិច្ចសិក្សានៅស្ថានីយទឹកស្អាតស្រុកសូទ្រនិគម ខេត្តសៀមរាប*

### ៤.២.៤ សន្និសីទ និងពិព័រណ៍ទឹកអូស្ត្រាលី (Ozwater'23) នៅប្រទេសអូស្ត្រាលី

ថ្ងៃទី៩-១៣ ខែឧសភា ឆ្នាំ២០២៣ សមាគមបានចូលរួមសន្និសីទ និងពិព័រណ៍ទឹកអូស្ត្រាលី (Ozwater'23) នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ជាមួយគណៈប្រតិភូកម្ពុជារួមមាន៖ តំណាងក្រសួង ឧរបន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័តសៀមរាប តំណាងស្ថានទូតអូស្ត្រាលីប្រចាំភ្នំពេញ កម្មវិធីCAPRED និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមសន្និសីទ Ozwater'23 ដើម្បីស្វែងយល់អំពីការគ្រប់គ្រងទឹករបស់ប្រទេសអូស្ត្រាលី គាំទ្រភាពធន់ខាងបរិស្ថាន និងសេដ្ឋកិច្ចនៃអនុតំបន់មេគង្គ។



*រូបភាពទី២៣៖ សន្និសីទ និងពិព័រណ៍ទឹកអូស្ត្រាលី (Ozwater'23) នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី*

## ៤.២.៥ វេទិកាស្តីពី «ទឹកស្អាត និងទឹកកខ្វក់នៅក្នុងប្រទេសឥណ្ឌូនេស៊ី»

ថ្ងៃទី៦-៨ ខែមិថុនា ឆ្នាំ២០២៣ សមាគមបានចូលរួមវេទិកា«ទឹកស្អាត និងទឹកកខ្វក់នៅក្នុងប្រទេសឥណ្ឌូនេស៊ី» និងការដាក់តាំងពិព័រណ៍ ដើម្បីសិក្សារៀនសូត្រពីចំណេះដឹងថ្មីៗ និងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសិក្ខាកាមដែលអញ្ជើញមកពី ៧ប្រទេសរួមមាន៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន កម្ពុជា វៀតណាម និងឡាវ។ គោលបំណងនៃការរៀបចំវេទិកា និងការដាក់តាំងពិព័រណ៍នេះគឺ ដើម្បីបង្ហាញពីការស្តារភាពល្បីល្បាញរបស់បណ្តាញការប្រើប្រាស់ទឹកនៅអាស៊ីអាគ្នេយ៍ (SEAWUN) ដល់សមាគមទឹកស្អាតផ្សេងៗទៀតនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍។



*រូបភាពទី២៤៖ វេទិកា និង ការដាក់តាំងពិព័រណ៍ទឹកស្អាត និងទឹកកខ្វក់ នៅប្រទេសឥណ្ឌូនេស៊ី*

## ៤.២.៦ វេទិកាទឹក លើកទី៥ និងសន្និសីទថ្នាក់តំបន់ ស្តីពីការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់ នៅប្រទេសថៃ

ថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ តបតាមការអញ្ជើញរបស់សមាគមទឹកម៉ាឡេស៊ី សមាគមបានដឹកនាំសមាជិករបស់ខ្លួនចំនួន ៣១នាក់(ស្រី ១២នាក់) ចូលរួមក្នុងវេទិកាទឹកលើកទី៥ និងសន្និសីទថ្នាក់តំបន់ស្តីពី «ការពង្រឹងការគ្រប់គ្រងទឹក និងបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក តាមរយៈបច្ចេកវិទ្យាបៃតង និងភាពជាដៃគូ» នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់។







*រូបភាពទី២៥៖ គណៈប្រតិភូកម្ពុជាទស្សនាអាងប្រព្រឹត្តិកម្មផលិតទឹកស្អាត*





*រូបភាពទី២៦៖ ពិធីបើកកម្មវិធីជាផ្លូវការ ស្តីពីវេទិកាទឹកលើកទី៥*




*រូបភាពទី២៧៖ ពិសាអាហារសាមគ្គី និងកសាងទំនាក់ទំនងធុរៈកិច្ច*

## ៤.២.៧ ការចូលរួមសន្និសីទទឹកវៀតណាម (Vietnam Water Week 2023)

ថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ២០២៣ សមាគមបានចូលរួមក្នុងកម្មវិធី Vietnam Water Week 2023 និងពិធីសម្ពោធបណ្តាញការងារនៅទីក្រុង BINH Duong, Vietnam ដែលបានបង្ហាញពីសារៈសំខាន់នៃកិច្ចសហការ និងការចែករំលែកពីចំណាប់អារម្មណ៍លើការគ្រប់គ្រងទឹកស្អាត និងទឹកកខ្វក់។ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ សមាគមបានចូលរួមកិច្ចប្រជុំបណ្តាញការងារសមាគមទឹកអាស៊ីអាគ្នេយ៍ (SEAWUN)។




*រូបភាពទី២៨៖ គណៈប្រតិភូសមាគមបានចូលរួមក្នុងកិច្ចប្រជុំ VIETNAM WATER WEEK 2023*



*រូបភាពទី២៩៖ គណៈប្រតិភូសមាគមបានចូលរួមក្នុងកិច្ចប្រជុំបណ្ដាញការងារសមាគមទឹកអាស៊ីអាគ្នេយ៍ SEAWUN*

### ៤.២.៨ ការចូលរួមសន្និសីទ និងពិព័រណ៍ទឹកវៀតណាម “Viet Water 2023”

ថ្ងៃទី១០-១២ ខែតុលា ឆ្នាំ២០២៣ សមាគមបានដឹកនាំសមាជិក និងបុគ្គលិកសមាគមចំនួន ៦១នាក់(ស្រី ២៤នាក់)ដើម្បីចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកវៀតណាម ២០២៣ នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាត សៃហ្គន ប្រទេសវៀតណាម ស្ដីពី «**ការពន្លឿនការបង្កើតថ្មីតាមតម្រូវការសម្រាប់ការគ្រប់គ្រងទឹកដ៏ឆ្លាតវៃ**»។




*រូបភាពទី៣០៖ គណៈប្រតិភូសមាគមបានចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកវៀតណាម “Viet Water 2023”*




*រូបភាពទី៣១៖ គណៈប្រតិភូក្នុងសន្និសីទ និងពិព័រណ៍ទឹកវៀតណាម “Viet Water 2023”*

# ៥.    កម្មវិធីកសាងសមត្ថភាពសមាជិក

## ៥.១  វគ្គបណ្តុះបណ្តាល

សមាគមបានសហការជាមួយមន្ទីរ ឧរបន និងសាខាពន្ធដារខេត្តបាត់ដំបង និងខេត្តកណ្តាល ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី**«សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»** បានចំនួន ២វគ្គ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលដើម្បីឱ្យអ្នកចូលរួមអាចរៀបរាប់បាន៖ ១)អំពីនីតិវិធីក្នុងការចុះបញ្ជីពន្ធដាររបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ២)ពីរបៀបនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និង ៣)អំពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ៖

១. ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារក្លាស់ស៊ី ខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុបចំនួន ២៨នាក់ (ស្ត្រី ១១នាក់) ដែលក្នុងនោះមានការអញ្ជើញចូលរួមពី លោកអនុប្រធានមន្ទីរ ឧរបន ខេត្តបាត់ដំបង និងប្រធានការិយាល័យទឹកស្អាត លោកអនុប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង និងមន្ត្រីជំនាញ ប្រតិបត្តិករចំនួន ២១នាក់ មកពី ១៥ស្ថានីយ និងរដ្ឋាករទឹកសាធារណៈខេត្តបាត់ដំបង។



*រូបភាពទី៣២៖ វគ្គបណ្តុះបណ្តាល*

២. ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន ៣៧នាក់ (ស្ត្រី ១១នាក់)មកពី ២៨ស្ថានីយ។



*រូបភាពទី៣៣៖ ការថតរូបអនុស្សាវរីយ៍ជាមួយគណអធិបតី*

# ៦. ភាពជាដៃគូ

## ៦.១ អនុស្សរណៈនៃការយោគយល់គ្នាជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគម(CWA) បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(CMA) ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់សមាជិករបស់សមាគមទាំងពីរ។



*រូបភាពទី ៣៤៖ ពិធីចុះអនុស្សរណៈយោគគ្នារវាង CWA និង CMA*

## ៦.២ អនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ សមាគមបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា លើកម្មវិធីសិក្សា«បរិញ្ញាបត្ររងវិស្វកម្មផ្គត់ផ្គង់ទឹកស្អាត និងប្រព័ន្ធទឹកក្នុងអគារ»។



*រូបភាពទី៣៥៖ ពិធីចុះអនុស្សរណៈយោគគ្នារវាង CWA និង ITC*

# ៧. ការផ្តល់សេវាកម្មផ្សេងៗ

## ៧.១ គូសផែនទីបណ្តាញជូនសមាជិក

ក្នុងឆ្នាំ២០២៣នេះ  សមាគមបានផ្តល់សេវាកម្មគូសប្លង់បណ្តាញប្រព័ន្ធទឹកស្អាតជូនស្ថានីយទឹកស្អាតសាលាលេខ ៥ ក្នុងតំបន់សេវាកម្មរបស់ស្ថានីយ។




*រូបភាពទី ៣៦៖ ផែនទីបណ្តាញស្ថានីយទឹកស្អាត សាលាលេខ៥*

## ៧.២. ផ្តល់សេវាសម្របសម្រួលការងារទឹកស្អាត

### ៧.២.១ ក្រុមហ៊ុន HITACHI ZOSEN CORPORATION

កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ សមាគមបានចុះកិច្ចព្រមព្រៀងសេវាកម្មជាមួយក្រុមហ៊ុន **HITZ** ដើម្បី៖

១. ផ្តល់ជាព័ត៌មាន និងការប្រឹក្សាយោបល់ទាក់ទងនឹងវិស័យទឹកស្អាតក្នុងប្រទេសកម្ពុជា
២. ការរៀបចំកិច្ចប្រជុំជាមួយនឹងភាគីពាក់ព័ន្ធ និងបុគ្គលសំខាន់ៗក្នុងវិស័យទឹកស្អាត
៣. រៀបចំ និង/ឬគាំទ្រការរៀបចំឯកសារដែលត្រូវផ្ញើមកប្រទេសកម្ពុជា
៤. ជួយបកប្រែឯកសារជាភាសាខ្មែរ។

### ៧.២.២ ក្រុមហ៊ុន ធីស៊ីយូ (T.C.U Polys Enterprise Co., Ltd)

សមាគមបានចុះកិច្ចព្រមព្រៀងផ្តល់សេវាកម្មឱ្យក្រុមហ៊ុនធីស៊ីយូ (T.C.U Polys Enterprise Co.,Ltd) ដើម្បីផ្តល់សេវាកម្មអញ្ជើញសមាជិកចូលរួមអបអរសាទរខួប ៧ឆ្នាំ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣។



*រូបភាពទី៣៧៖ ការថតរូបអនុស្សាវរីយ៍របស់សមាជិកក្នុងកម្មវិធី*

### ៧.២.៣ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើការលក់ទឹកដុំ (Bulk Water_CAPRED)

ក្រោមកិច្ចសហការរវាងសមាគម និងកម្មវិធី CAPRED បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់អំពី«គំរូអាជីវកម្មផ្គត់ផ្គង់ទឹកដុំ»។ ការសិក្សានេះបានធ្វើនៅក្នុងខេត្តចំនួនពីរគឺ ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ តាមរយៈការសិក្សានេះ កម្មវិធី CAPRED បានរៀបចំជាករណីសិក្សាមួយចំនួនដើម្បីយកមកពិគ្រោះយោបល់ពីនីតិវិធីក្នុងការលក់ទឹកដុំជាមួយអ្នកពាក់ព័ន្ធ ជាពិសេសប្រតិបត្តិករក្នុងតំបន់គោលដៅ។ នៅចុងបញ្ចប់នៃកិច្ចប្រជុំ អ្នកចូលរួមអាចមានលទ្ធភាព៖

1. រៀបរាប់បានខ្លឹមសារមួយចំនួននៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត
2. ពន្យល់បានពីគំរូអាជីវកម្មផ្គត់ផ្គង់ទឹកដុំ( លក់ទឹកដុំ )។

ជាលទ្ធផលអ្នកចូលរួមសរុបចំនួន ២០នាក់( ស្រី ៦នាក់ ) មកពី ៩ស្ថានីយ។



*រូបភាពទី៣៨៖ បទបង្ហាញអំពីគំរូអាជីវកម្មទឹកដុំ ដោយតំណាងកម្មវិធី CAPRED*

# ៨. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍

## ៨.១ គម្រោងពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត ( WaterAid )

### ៨.១.១. ការឧបត្ថម្ភធនលើការភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ

នៅឆ្នាំ២០២៣នេះ គម្រោងបានឧបត្ថម្ភធនក្នុងការភ្ជាប់បណ្ដាញទឹកស្អាតជូនគ្រួសារក្រីក្រចំនួន ៤៧គ្រួសារ ដោយមានការចូលរួមបដិភាគពីស្ថានីយទឹកស្អាតចំនួន ៥ស្ថានីយរួមមាន៖ ១)ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្ដុល ២) ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ៥ ៣)ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម ៤)ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម និង ៥)ស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំអំពិលទឹក។

### ៨.១.២ ការប្រមូលទិន្នន័យចុងគ្រា

គម្រោងបានសហការជាមួយរដ្ឋបាលស្រុក ចំនួន៦៖ ១.ស្រុកសាមគ្គីមានជ័យ ២.ស្រុកកំពង់ត្រឡាច ក្នុងខេត្តកំពង់ឆ្នាំង ៣.ស្រុកសំរោងទង ៤.ស្រុកថ្ពង ក្នុងខេត្តកំពង់ស្ពឺ ៥.ស្រុកអង្គស្នួល ៦.ស្រុកកណ្ដាលស្ទឹង ក្នុងខេត្តកណ្ដាល និង មន្ទីរ ឧរបន ខេត្តកំពង់ស្ពឺ ចុះប្រមូលទិន្នន័យចុងគ្រា ដើម្បីបិទបញ្ចប់គម្រោងក្នុងត្រីមាសទី១ ឆ្នាំ២០២៣។ ជាលទ្ធផល ក្រុមការងារបានប្រមូលទិន្នន័យពីអាជ្ញាធរមូលដ្ឋានចំនួន ៣៥ឃុំ និងសហគមន៍ចំនួន ៣៥ភូមិ (ក្នុងឃុំទាំង៣៥) ដែលមានអ្នកចូលរួមសរុបចំនួន ៧៩៣នាក់ (ស្រី ៣៨១នាក់)។





*រូបភាពទី៣៩៖ ការប្រមូលទិន្នន័យចុងគ្រានៅស្រុកសាមគ្គីមានជ័យ និងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*

## ៨.២ គម្រោងបង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីឆ្នើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន ( WaterAid )

### ៨.២.១ កិច្ចប្រជុំផ្សព្វផ្សាយ

គម្រោងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយសហគមន៍ស្ដីពី **«សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងទស្សនកិច្ចសិក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត»** ចំនួន ៤លើក ដើម្បីឱ្យអ្នកចូលរួមអាច៖ ១)ពន្យល់បានពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ និងការទុកដាក់ទឹកឱ្យមានសុវត្ថិភាព ២)លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ជាពិសេសគ្រួសារក្រីក្រឱ្យបានភ្ជាប់បណ្ដាញទឹកស្អាត និង៣)លើកទឹកចិត្តដល់អ្នកចូលរួមជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ

ក្នុងសហគមន៍។ សមាសភាពអ្នកចូលរួមរួមមាន៖ ក្រុមប្រឹក្សាឃុំ គ្រូបង្រៀន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងជនពិការ ប្រជាពលរដ្ឋ តំណាងអង្គការវ៉េតធីអេត និងបុគ្គលិកសមាគម។

- **លើកទី១៖** ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ រៀបចំនៅ**ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ ព្រែកអំបិល** នៅភូមិព្រែកតាឡៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល។ សមាសភាពអ្នកចូលរួមចំនួន ២៩នាក់(ស្រី ១៦នាក់)។
- **លើកទី២៖** ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ រៀបចំនៅ**ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល** ស្ថិតនៅភូមិព្រែកតាតិន ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល។ សមាសភាពអ្នកចូលរួមចំនួន ២៦នាក់(ស្រី ១៣នាក់)។
- **លើកទី៣៖** ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ រៀបចំនៅ**ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្រើយស្លា** ស្ថិតនៅភូមិព្រែកបាឡាត់ធឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល។ សមាសភាពអ្នកចូលរួមចំនួន ២៣នាក់(ស្រី ៥នាក់)។
- **លើកទី៤៖** ថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣ រៀបចំនៅ**ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា** នៅភូមិក្បាលកោះកើត ឃុំកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្តាល។ សមាសភាពអ្នកចូលរួមចំនួន ៣៥នាក់(ស្រី ២១នាក់)។



*រូបភាពទី ៤០៖ លោក ហ៊ាង ដារ៉ា ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល*

## ៨.២.២ វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ

សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពី«**វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត**» ចំនួន២វគ្គ៖

- ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ធ្វើនៅសាលាស្រុកស្អាង ដែលមានអ្នកចូលរួមសរុបចំនួន ១៩នាក់(ស្រី ២នាក់)
- ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ធ្វើនៅសាលាស្រុកល្វាឯម ដែលមានអ្នកចូលរួមសរុប ១៤នាក់(ស្រី ២នាក់)។

## ៨.២.៣ ការគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ

ឆ្នាំ២០២៣ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន២ បានទទួល និងយល់ព្រមគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ។ ជាលទ្ធផលគ្រួសារក្រីក្រចំនួន ៤០គ្រួសារ (មានសមាជិកគ្រួសារប្រមាណ ១៧១នាក់) បានភ្ជាប់បណ្តាញទឹកស្អាតពីស្ថានីយទាំងពីរនេះ ។



*រូបភាពទី៤១៖ ការតភ្ជាប់ទឹកស្អាតរបស់គ្រួសារក្រីក្រ*

## ៨.៣. គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា ( WaterAid)

### ៨.៣.១ កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

គម្រោងបានរៀបចំកិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ៤លើក៖

- **លើកទី១៖** ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ មានកិច្ចប្រជុំចំនួនពីរ៖
  ១. សម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម៖ រៀបចំនៅសាលាឃុំស្វាយ ស្ថិតនៅភូមិត្រពាំងថ្ម ឃុំស្វាយ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប ២៣នាក់ (ស្រី ៤នាក់)។
  ២. សម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់៖ រៀបចំនៅសាលាឃុំសេដ្ឋី ស្ថិតនៅភូមិរ៉ា ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប ១៥នាក់ (ស្រី ៧នាក់)។
- **លើកទី២៖** ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ មានកិច្ចប្រជុំចំនួនពីរ៖
  ១. សម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម រៀបចំនៅសាលាឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប ២០នាក់ (ស្រី ៩នាក់)។
  ២. សម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មករា ស្វាយជុក រៀបចំនៅសាលាឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុប ១៣នាក់ (ស្រី ៤នាក់)។



*រូបភាពទី៤២៖ កិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅឃុំពាម*

### ៨.៣.២ ប្រជុំឆ្លុះបញ្ចាំងលទ្ធផលការអនុវត្តគណនេយ្យភាព វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានចូលរួមកិច្ចប្រជុំឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តគណនេយ្យភាព វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅសាលប្រជុំសាលាស្រុកសាមគ្គីមានជ័យ។ កិច្ចប្រជុំមានគោលបំណងចំនួន ៣ ដូចខាងក្រោម៖

១. លើកកម្ពស់ការផ្តល់សេវាសាធារណៈ វិស័យទឹកស្អាតដល់កម្រិតគុណភាពក្នុងសហគមន៍
២. ឆ្លុះបញ្ចាំងគ្នាពីតួនាទី ភារៈកិច្ចទំនួលខុសត្រូវរបស់អ្នកទទួលសេវា និងអ្នកផ្តល់សេវាទឹកស្អាត
៣. បង្កើនឱ្យមានការប្រកួតប្រជែង ចំពោះអ្នកផ្គត់ផ្គង់ទឹកស្អាត ដើម្បីបង្កើនសេវាផ្គត់ផ្គង់ទឹកឱ្យកាន់តែមានប្រសិទ្ធិភាពទូទាំងស្រុកសាមគ្គីមានជ័យ។

ជាលទ្ធផល ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ស្ថានីយ ទទួលបាន៣ានរង្វាន់ជាប្រតិបត្តិករឆ្នើមប្រចាំស្រុកសាមគ្គីមានជ័យ ដែលមានរាយឈ្មោះដូចខាងក្រោម៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ ទទួលបានចំណាត់ថ្នាក់លេខ១ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន ៣០ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតបានល្អប្រសើរ។
២. ក្រុមហ៊ុនលង្វែកឱរេឡុបម៉ិនវ៉តជើរសឺបផ្លាយ ឯ.ក ទទួលបានចំណាត់ថ្នាក់លេខ ២ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន ២៥ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតបានល្អប្រសើរ។
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហេងអៀម ទទួលបានចំណាត់ថ្នាក់លេខ ៣ ជាប្រតិបត្តិករឆ្នើម ព្រមទាំងទទួលបាននាឡិកាទឹកចំនួន២០ ជារង្វាន់លើកទឹកចិត្តក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតបានល្អប្រសើរ។

ក្នុងនោះដែរជាការលើកទឹកចិត្តជូនប្រតិបត្តិករដែលពុំបានទទួលចំណាត់ថ្នាក់ គម្រោងបានផ្តល់ជូននាឡិកាទឹកចំនួន ១០គ្រឿង(ក្នុង១ស្ថានីយ) ជូនដល់ស្ថានីយចំនួន៣ ផ្សេងទៀត។

## ៨.៤ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់រកទុនកម្ចី (Water.org)

### ៨.៤.១ វគ្គបណ្តុះបណ្តាល

សមាគមបានសហការជាមួយក្រុមហ៊ុន អ៊ី-ផៅវ័រ ស៊ីស៊ីអិល (E-Power CCL Co., Ltd) ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី **«ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»** នៅការិយាល័យរបស់សមាគម។

វគ្គបណ្តុះបណ្តាលមានគោលបំណងឱ្យអ្នកចូលរួមអាច៖

១. ពិនិត្យទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលបានបញ្ជូនមកកាន់សមាគម
២. ស្វែងយល់អំពីរបៀបបញ្ចូលទិន្នន័យអាជីវកម្មចូលក្នុង DMS
៣. រៀបចំរបាយការណ៍ហិរញ្ញវត្ថុចេញពីប្រព័ន្ធ DMS។



*រូបភាពទី៤២៖ វគ្គបណ្តុះបណ្តាល*

វគ្គបណ្តុះបណ្តាលមានអ្នកចូលរួមចំនួន ១៩នាក់(ស្រី ៧នាក់) មកពីប្រតិបត្តិករ ១១ស្ថានីយ។

## ៨.៥ គម្រោងកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត ( Water.org )

### ៨.៥.១ ការចុះកិច្ចព្រមព្រៀង

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានចុះកិច្ចព្រមព្រៀងជាមួយអង្គការ Water.org ទទួលយកគម្រោង **«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត»** មកអនុវត្តន៍។ គម្រោងនេះមានទិសដៅ **«ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ប្រជាជនកម្ពុជាជាពិសេសប្រជាពលរដ្ឋក្រីក្រ»**។ គម្រោងនេះមានលទ្ធផលរំពឹងទុកចំនួនបីដូចខាងក្រោម៖

១) ប្រតិបត្តិករយ៉ាងតិចចំនួន ៩ស្ថានីយ នឹងទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ

២) តំណថ្មីចំនួន ២០.០០០ នឹងកើនឡើង តាមរយៈសកម្មភាពសម្របសម្រួលរបស់គម្រោងដើម្បីឱ្យប្រជាជនមានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ និង

៣) ប្រតិបត្តិករនឹងធ្វើឱ្យប្រសើរឡើងនូវគុណភាពទឹកស្អាត ដោយអនុលោមតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិជាពិសេសប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥។




*រូបភាពទី៤៣៖ ការចុះកិច្ចព្រមព្រៀងទទួលយកគម្រោងរវាង សមាគម និងអង្គការ Water.org*

### ៨.៥.២ ការសម្របសម្រួលទស្សនកិច្ចសិក្សា

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានរៀបចំទស្សនកិច្ចសិក្សារបស់ម្ចាស់មូលនិធិនៃអង្គការ Water.org ទៅទស្សនកិច្ចសិក្សានៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង និងជួបជាមួយអតិថិជនចំនួន ២គ្រួសារផងដែរ។

### ៨.៥.៣ សិក្ខាសាលាផ្សព្វផ្សាយគម្រោង

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោងស្តីពី**«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត»** នៅសណ្ឋាគារសាន់វ៉េ។ សិក្ខាសាលានេះមានអ្នកចូលរួមសរុបចំនួន ៥៩នាក់(ស្រី ១៧នាក់) មានប្រតិបត្តិករចំនួន ៤១នាក់មកពី ៣៨ស្ថានីយ។

ក្នុងថ្ងៃដដែល សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត រៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី«ប្រកាសអនុញ្ញាឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»។ សិក្ខាសាលាតម្រង់ទិសមានគោលបំណង៖ ១).ស្វែងយល់អំពីឯកសារគតិយុត្តពាក់ព័ន្ធទៅនឹងសេវាទឹកស្អាតតាមបំពង់ ២).រៀបរាប់បានពីចំណុចសំខាន់ៗដែលមាននៅក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និង ៣).ពិភាក្សាអំពីចំណុចដែលអនុវត្តបានល្អ និងចំណុចដែលត្រូវកែលម្អដើម្បីអនុវត្តប្រកាសឱ្យបានត្រឹមត្រូវ។



*រូបភាពទី៤៤៖ សិក្ខាសាលាផ្សព្វផ្សាយគម្រោង*

## ៨.៥.៤ វគ្គបណ្តុះបណ្តាល

### *ក. ការធ្វើទីផ្សារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«ការធ្វើទីផ្សារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារពូលូវ៉េ។ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលសិក្ខាកាមអាចមានលទ្ធភាព៖១.រៀបរាប់អំពីវិធីសាស្ត្រធ្វើទីផ្សារក្នុងការជំរុញកំណើនតំណ ២.អាចកំណត់ឧបករណ៍/បច្ចេកទេសទីផ្សារក្នុងការជម្រុញឱ្យមានកំណើនតំណ ៣.ធ្វើឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាត និងបង្កើតអាជីវកម្មមួយប្រកបដោយជោគជ័យ និងមានទំនាក់ទំនងល្អជាមួយអតិថិជន។ វគ្គបណ្តុះបណ្តាលនេះមានអ្នកចូលរួមសរុបចំនួន ៣១នាក់(ស្រី ១២នាក់) ដែលមានការអញ្ជើញមកពីតំណាងអគ្គនាយកដ្ឋានទឹកស្អាត តំណាងអង្គការ Water.org តំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី (LOLC) និងប្រតិបត្តិករ មកពី ១៨ស្ថានីយ។

### *ខ. ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ*

១. ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ សមាគមបានប្រជុំតាមអនឡាញជាមួយប្រតិបត្តិករ ដើម្បីពិភាក្សាអំពី **«តម្រូវការទិន្នន័យសម្រាប់បើកទិន្នន័យដើមគ្រា»**។ កិច្ចប្រជុំនេះបានពិភាក្សាអំពីតម្រូវការឯកសារ និងទិន្នន័យដែលត្រូវការដើម្បីប្រមូលសម្រាប់ការបើកសមតុល្យ។ ជាលទ្ធផលមានអ្នកចូលរួមសរុបចំនួន ៣៨នាក់ មកពីស្ថានីយទឹកស្អាត ២៨ស្ថានីយ និងក្រុមហ៊ុនអ៊ីផៅវ័រ ស៊ីស៊ីអិល ឯ.ក ។

២. ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ សមាគមបានសហការជាមួយក្រុមហ៊ុន អ៊ី-ផៅវ័រ ស៊ីស៊ីអិល ឯ.ក រៀបចំវគ្គបណ្តុះបណ្តាលស្តីពី**«មូលដ្ឋានគ្រឹះគណនេយ្យសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»**។ សមាសភាពចូលរួម

ក្នុងវគ្គបណ្ដុះបណ្ដាលមានចំនួន ៤២នាក់(ស្រី ១៨នាក់) ដែលអញ្ជើញមកពីអគ្គនាយកដ្ឋានទឹកស្អាត តំណាងអង្គការ Water.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២នាក់។



*រូបភាពទី៤៥៖ ការធ្វើបទបង្ហាញដោយអ្នកជំនាញមកពីក្រុមហ៊ុន អ៊ី-ផៅវ័រ*

៣. ថ្ងៃទី២៤-២៥ ខែសីហា ឆ្នាំ២០២៣ សមាគមបានសហការជាមួយក្រុមហ៊ុន អ៊ី-ផៅវ័រ ស៊ីស៊ីអិល ឯ.ក រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី«**ប្រព័ន្ធគណនេយ្យពេញលេញ E-Water Software**»។ អ្នកចូលរួមចំនួន ៤៨នាក់(ស្រី ២៣នាក់) អញ្ជើញមកពីអគ្គនាយកដ្ឋានទឹកស្អាត និងប្រតិបត្តិករចំនួន ៣៩នាក់។



*រូបភាពទី៤៦៖ បទបង្ហាញស្ដីពីប្រព័ន្ធគណនេយ្យពេញលេញ - លោក ខឹម សំណាង ក្រុមហ៊ុន អ៊ី-ផៅវ័រ ស៊ី ស៊ី អិល ឯ.ក*

## គ. ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត រៀបចំវគ្គបណ្ដុះបណ្ដាលជូនប្រតិបត្តិករដូចខាងក្រោម៖

១. វគ្គបណ្ដុះបណ្ដាលស្ដីពី«**បច្ចេកទេសតេស្ដគុណភាពទឹកស្អាត និងវិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួតនិងគ្រោះទឹកជំនន់ សម្រាប់ការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត**» ដែលបានរៀបចំជាពីរក្រុម៖

- **ក្រុមទី១៖** ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សមាសភាពចូលរួមចំនួន ៣៧នាក់(ស្រី ១២នាក់)។
- **ក្រុមទី២៖** ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ សមាសភាពចូលរួមចំនួន ៣៦នាក់(ស្រី ៧នាក់)។



*រូបភាពទី៤៧៖ វគ្គបណ្ដុះបណ្ដាលស្ដីពី បច្ចេកទេសតេស្ដគុណភាពទឹកស្អាត*

២. វគ្គបណ្តុះបណ្តាលស្តីពី«**ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត» និង«គោលការណ៍ ស៥»** ថ្ងៃទី២០-២១ ខែធ្នូ ឆ្នាំ២០២៣ នៅភោជនីយដ្ឋានទន្លេបាសាក់២។ សមាសភាពចូលរួមមានចំនួន ៣៥នាក់(ស្រី ១០នាក់)។



*រូបភាពទី៤៨៖ វគ្គបណ្តុះបណ្តាលស្តីពី«ផែនការសុវត្ថិភាពទឹក » និង«គោលការណ៍ ស៥»*

## ៨.៥.៥ សិក្ខាសាលាផ្សព្វផ្សាយ«ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត»

ក្រោមកិច្ចសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ**«ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត»** តាមរយៈជំនួយឧបត្ថម្ភពីអង្គការ Water.org។ សិក្ខាសាលានេះមានការចូលរួមជាអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា រដ្ឋលេខាធិការ** និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួង ឧវបន។ សិក្ខាសាលាផ្សព្វផ្សាយនេះរៀបចំឡើងក្នុងគោលបំណងឱ្យភាគីពាក់ព័ន្ធទាំងអស់យល់កាន់តែច្បាស់អំពីខ្លឹមសារនៃច្បាប់ថ្មី ជាពិសេសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បានយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត។ ចំនួនអ្នកចូលរួមសរុបមាន ៣១៦នាក់ (ស្រី ៨៣នាក់) អញ្ជើញមកពីក្រសួង ឧវបន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ តំណាងដៃគូអភិវឌ្ឍន៍ អង្គការ Water.org និងសមាជិកសមាគម។



*រូបភាពទី៤៩៖ សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ*

## ៨.៥.៦ ទស្សនកិច្ចសិក្សា

### ក. ទស្សនកិច្ចសិក្សាក្រៅប្រទេស

ថ្ងៃទី២៥-២៩ ខែមិថុនា ឆ្នាំ២០២៣ សមាគមបានរៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី ដែលមានសមាសភាពចូលរួមពី តំណាងអគ្គនាយកដ្ឋានទឹកស្អាត ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅក្នុងគម្រោង បុគ្គលិកអង្គការ Water.org និងបុគ្គលិកសមាគម សរុបចំនួន ១៤នាក់(ស្រី ៤នាក់)ក្រោមការឧបត្ថម្ភរបស់អង្គការ Water.org ។ ខាងក្រោមនេះជាលទ្ធផលនៃដំណើរទស្សនកិច្ចសិក្សា៖

១. ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣៖ ចូលរួមក្នុងកិច្ចប្រជុំដើម្បីស្វែងយល់អំពី ១)តួនាទីរបស់សមាគមផ្គត់ផ្គង់ទឹកជាតិឥណ្ឌូនេស៊ី PERPAMSI និងទិដ្ឋភាពទូទៅនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងទីក្រុង (PDAMs) ២)ការណែនាំកម្មវិធី Water Equity ៣)ការចែករំលែកភាពជាដៃគូរវាងក្រុមហ៊ុន Grenex និងរដ្ឋាករផ្គត់ផ្គង់ទឹកស្អាត Bekasi ក្នុងការកាត់បន្ថយការបាត់បង់ទឹក។

២. ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣៖ ចូលរួមក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៍លើផ្នែកហិរញ្ញវត្ថុប្រើប្រាស់តាមរយៈធនាគារ និងបង្ហាញអំពីទស្សនៈរបស់ PDAM Sleman, PDAM Batang និង Bank Sleman។ គណប្រតិភូកម្ពុជាបានអញ្ជើញទស្សនាប្រាសាទ Borobudur ដែលជាប្រាសាទព្រះពុទ្ធសាសនាដែលត្រូវបានកសាងឡើងតាំងពីសតវត្សទី៨ នៃគ្រិះសករាជ។

៣. ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣៖ គណប្រតិភូកម្ពុជាបានទៅទស្សនាអាងប្រព្រឹត្តិកម្មសម្អាតទឹក(WTP) ដែលគ្រប់គ្រងដោយក្រុមហ៊ុន Grenex នៅទីក្រុង Bakasi។



*រូបភាពទី៥០៖ ការថតរូបអនុស្សាវរីយ៍ក្រោយបញ្ចប់កិច្ចប្រជុំ*

### ខ. ទស្សនកិច្ចសិក្សាក្នុងប្រទេស

សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួនពីរ (ស្ថានីយទឹកស្អាតស្វាយរមៀត និងស្ថានីយទឹកស្អាត ឡេង ខៀវ ព្រែកអំបិល) ក្នុងការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងបទពិសោធន៍ជោគជ័យក្នុងការគ្រប់គ្រងអាជីវកម្ម។





*រូបភាពទី៥១៖ ទស្សនកិច្ចសិក្សានៅ ស្ថានីយទឹកស្អាត ឡេង ខៀវ ព្រែកអំបិល និងស្ថានីយទឹកស្អាតស្វាយរមៀត*

## ៨.៥.៧ ការសម្របសម្រួលកម្មវិធីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និង ស្ថាប័នហិរញ្ញវត្ថុ

### *ក. ការភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការផ្តល់ហិរញ្ញប្បទានក្នុងវិស័យទឹកស្អាត*

១. ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ សមាគមបានសម្របសម្រួលអញ្ជើញប្រតិបត្តិករចំនួន ១០ស្ថានីយ ចូលរួមក្នុងសិក្ខាសាលាស្តីពី«ការចាប់ផ្តើមកម្មវិធីឥណទានទឹកស្អាត»នៅសណ្ឋាគារភ្នំពេញ ដែលសហការរៀបចំដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងអង្គការ Water.org។ សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងផ្តល់ជាវេទិកាសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (Bank & FIs) និងប្រតិបត្តិករ ដើម្បីរកដំណោះស្រាយលើការផ្តល់ និងទទួលបានឥណទាន។ ជាងនេះទៅទៀតសិក្ខាសាលានឹងពិនិត្យមើលលទ្ធភាពផ្គូរផ្គងនូវតម្រូវការ និងលក្ខខណ្ឌរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ សិក្ខាសាលានេះមានការចូលរួមពីមន្ត្រីជាន់ខ្ពស់មកពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ព្រមទាំងតំណាងមកពីសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា សរុបអ្នកចូលរួមចំនួន ៣១នាក់។



*រូបភាពទី៥២៖ សិក្ខាសាលាស្តីអំពីការចាប់ផ្តើមកម្មវិធីឥណទានទឹកស្អាត នៅសណ្ឋាគារភ្នំពេញ*

២. ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ តំណាងអង្គការ Water.org សមាគម CWA និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា(SME bank) បានជួបប្រជុំ ដើម្បីណែនាំអំពីទិដ្ឋភាពទូទៅនៃគម្រោង និងពិភាក្សាអំពីរបៀបគាំទ្រប្រតិបត្តិករទទួលបានហិរញ្ញប្បទានក្នុងការអភិវឌ្ឍន៍វិស័យទឹកស្អាតនៅកម្ពុជា។




*រូបភាពទី៥៣៖ តំណាងអង្គការ WATER.ORG សមាគម CWA និងធនាគារ SME BANK*

៣. អង្គការ Water.org សមាគម CWA ធនាគារ SME និងម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ស្ថានីយបាន ជួបប្រជុំ ដើម្បីពិភាក្សាអំពីដំណើរការកម្ចី និងរបៀបគាំទ្រដល់ប្រតិបត្តិករក្នុងការទទួលបានហិរញ្ញប្បទាន។
៤. ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ សមាគម និងក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី( ស៊ីប៊ីស៊ី )មានកិច្ចប្រជុំ ដើម្បីណែនាំអំពីសមាគម អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ( ខេមបូឌា )ខូអិលធីឌី( ស៊ីប៊ីស៊ី ) និងពិភាក្សាពីភាពជាដៃគូនាពេលអនាគត។
៥. ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ អង្គការ Water.org សមាគម CWA និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) មានកិច្ចប្រជុំដើម្បីណែនាំអំពីសមាគម អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងពិភាក្សាពីភាពជាដៃគូនាពេលអនាគត។

### ខ. ការសម្របសម្រួលកម្ចី

ក្រុមការងារគម្រោងបានសម្របសម្រួលជាមួយធនគារ SME ក្នុងការផ្តល់ប្រាក់កម្ចីដល់ប្រតិបត្តិករចំនួន ១០ ស្ថានីយ។ ជាលទ្ធផលប្រតិបត្តិករចំនួន ៦ស្ថានីយ ទទួលបានការអនុម័តកម្ចី ដែលមានទំហំទឹកប្រាក់ ២.៤៣៥.០០០ ដុល្លារអាមេរិក។ លើសពីនេះ សមាគមក៏បានសម្របសម្រួលឱ្យមានការបញ្ចុះការប្រាក់ ដោយយោងលើអនុស្សរណៈយោគយល់គ្នា រវាងសមាគម CWA និងធនគារ SME ដូច្នេះខាងធនាគារ SME បានបញ្ចុះថ្លៃអត្រាការប្រាក់បន្ថែមចំនួន ០,២៥% ក្នុងមួយឆ្នាំជូនដល់ប្រតិបត្តិករជាសមាជិកសមាគម។

កម្ចីទាំងនោះត្រូវបានយកមកប្រើប្រាស់ក្នុងគោលបំណងដើម្បីៈ ១)ពង្រីកបណ្តាញបំពង់ទឹកស្អាត ២)ប្តូរ និងបន្ថែមបំពង់ទឹកស្អាត ៣)ដំឡើងម៉ាស៊ីនបូមទឹក ៤)កែលម្អអាងប្រព្រឹត្តិកម្ម និង ៥)ដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ។

## ៨.៥.៨ ការឧបត្ថម្ភធនលើឧបករណ៍តេស្តគុណភាពទឹកស្អាត

គម្រោងបានសម្របសម្រួលក្នុងការទិញឧបករណ៍តេស្តគុណភាពទឹកស្អាតទាំង ៥ប៉ារ៉ាម៉ែត្រ និងឧបករណ៍វាស់សម្ពាធទឹកចុងបណ្តាញជូនប្រតិបត្តិករក្នុងគម្រោង។ ជាលទ្ធផលប្រតិបត្តិករចំនួន ២២ស្ថានីយបានស្នើសុំឧបករណ៍តេស្តគុណភាពទឹកស្អាត ក្រោមមូលនិធិឧបត្ថម្ភធនរបស់គម្រោង។ ក្នុងនោះដែរថវិកាសរុបសម្រាប់ទិញឧបករណ៍តេស្តគុណភាពទឹកមានចំនួន ២០.៧៧៣,៥០ដុល្លារអាមេរិក ដែលឧបត្ថម្ភធនដោយគម្រោងចំនួនទឹកប្រាក់ ៨.៥៩៦,៥០ ដុល្លារអាមេរិក និងចូលរួមបដិភាគពីប្រតិបត្តិករមានចំនួនទឹកប្រាក់ ១២.១៧៧,០០ដុល្លារអាមេរិក។

## ៨.៥.៩ កិច្ចប្រជុំជាមួយ អគ្គនាយកដ្ឋានទឹកស្អាត

ក្រុមការងារគម្រោងបានសម្របសម្រួលកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាតចំនួន ៤លើកៈ

១. **លើកទី១ៈ** ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ដើម្បីពិភាក្សាអំពីទិដ្ឋភាពទូទៅនៃគម្រោង និងស្វែងរកការគាំទ្រគម្រោងពីអគ្គនាយកដ្ឋានទឹកស្អាត ។
២. **លើកទី២ៈ** ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីពិភាក្សាអំពីផែនការកសាងសមត្ថភាពផ្នែកបច្ចេកទេសដល់ប្រតិបត្តិករ។
៣. **លើកទី៣ៈ** ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ដើម្បីពិភាក្សាលើរបៀបវារៈនៃវគ្គបណ្តុះបណ្តាលបច្ចេកទេស និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល។
៤. **លើកទី៤ៈ** ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីពិភាក្សាលើបញ្ហាប្រឈមរបស់ប្រតិបត្តិករទឹកស្អាតលើបញ្ហាពន្ធដារ។

### ៨.៥.១០ ការផលិតវីដេអូអប់រំ

ក្រុមការងារគម្រោងបានសម្របសម្រួលផលិតវីដេអូអប់រំស្តីអំពីសេវាទឹកស្អាតដូចខាងក្រោម៖

១. វីដេអូអប់រំខ្លីស្តីពី«**សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់**» ដែលបានសហការ និងផលិតនៅទីតាំងស្ថានីយទឹកស្អាតកំពង់ចំលង និងស្ថានីយទឹកស្អាតស្វាយរមៀត។
តំណភ្ជាប់៖ https://www.youtube.com/watch?v=TNMt44dX3VQ&t=55s




*រូបភាពទី៥៤៖ រូបភាពដកស្រង់ចេញពីវីដេអូស្តីពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត*

២. គម្រោងបានផ្សព្វផ្សាយពីការប្រកួតប្រជែងផលិតវីដេអូអប់រំខ្លីស្តីអំពីសេវាផ្គត់ផ្គង់ទឹកស្អាត។ ជាលទ្ធផលមានវីដេអូចំនួនពីរដែលបានផ្ញើមកសមាគម ហើយគណៈកម្មការពិនិត្យលើវីដេអូទាំងពីរនោះ ឃើញថាមិនអាចទទួលយកបាន។ គម្រោងសម្រេចថា មិនបន្តការផ្សព្វផ្សាយអំពីការប្រកួតប្រជែងផលិតវីដេអូអប់រំខ្លីទៀតទេ។

## ៨.៦ គម្រោងសមត្ថភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម (CO-SAVED_AEA)

### ៨.៦.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង

គម្រោងបានរៀបចំកិច្ចប្រជុំរវាងអាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ស្តីពី«**ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់សហការជាមួយគម្រោងសមត្ថភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម**» ចំនួន ២ប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ រៀបចំនៅសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ។ សមាសភាពអ្នកចូលរួមសរុបចំនួន ៧នាក់(ស្រី ១នាក់)។
២. ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ រៀបចំនៅសាលាស្រុកកំពង់ត្រាច ខេត្តកំពត។ សមាសភាពអ្នកចូលរួមសរុបចំនួន ១៣នាក់(ស្រី ៤នាក់)។

សមាគមបានរៀបចំកិច្ចប្រជុំស្តីពី«**ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត**» នៅការិយាល័យសមាគម។ អង្គប្រជុំបានកំណត់យក ស្រុកកំពង់សីលា ខេត្តព្រះសីហនុ និងស្រុកកំពង់ត្រាច ខេត្តកំពត ជាតំបន់គោលដៅ។ ចំនួនអ្នកចូលរួមសរុប ១២នាក់(ស្រី ៦នាក់) មកពីស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់សីលា ១នាក់ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតភ្នំមាស ១នាក់ អង្គការ AEA ៥នាក់ និងបុគ្គលិកសមាគម ៥នាក់។




*រូបភាពទី៥៥៖ កិច្ចប្រជុំជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត*

## ៨.៦.២ សិក្សាលម្អិតលើការពង្រីកបណ្តាញបំពង់ទឹកស្អាត

ថ្ងៃទី២១-២៤ ខែកុម្ភៈ ឆ្នាំ២០២៣ សមាគមបានចុះសិក្សាលម្អិតលើការពង្រីកបណ្តាញបំពង់ទឹកស្អាត នៅស្រុកកំពង់សីលា និងស្រុកកំពង់ត្រាច។ ជាលទ្ធផល ភូមិចំនួន ១៣ ត្រូវបានជ្រើសរើសសម្រាប់ពង្រីកបណ្តាញទឹកស្អាត (ស្ថានីយផ្គត់ផ្គង់ទឹកស្អាតភ្នំមាស ៨ភូមិ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់សីលា ៥ភូមិ)។




*រូបភាពទី៥៦៖ ការចុះសិក្សាលម្អិតពីការពង្រីកបណ្តាញបំពង់ទឹកស្អាត*

## ៨.៦.៣ ការដេញថ្លៃបំពង់ទឹកស្អាត



*រូបភាពទី៥៧៖ ការដេញថ្លៃផ្គត់ផ្គង់បំពង់ទឹកស្អាត (នៅការិយាល័យសមាគម)*

សមាគមបានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពី«ការដេញថ្លៃការផ្គត់ផ្គង់បំពង់ទឹកស្អាត» លើគេហទំព័រសមាគម ក៏ដូចជាប្រព័ន្ធទំនាក់ទំនងសង្គម។ ជាលទ្ធផលមានក្រុមហ៊ុនចំនួន ៩ បានដាក់ពាក្យដេញថ្លៃក្នុងការផ្គត់ផ្គង់បំពង់ទឹកស្អាតទៅដល់ស្ថានីយពីរ គឺស្ថានីយផ្គត់ផ្គង់ទឹកស្អាតភ្នំមាស និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់សីលា ដែលទទួលបានការវិនិយោគពីគម្រោង។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ សមាគមបានបើកកញ្ចប់ដេញថ្លៃផ្គត់ផ្គង់បំពង់ទឹកស្អាត។ ក្រុមហ៊ុន ធី ស៊ី យូ ប៉ូលី អេធើប្រាយ (T.C.U Polys Enterprise) ជាអ្នកទទួលការផ្គត់ផ្គង់បំពង់ទឹកស្អាត។

## ៨.៦.៤ វគ្គបណ្តុះបណ្តាល

### *ក. តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត*

សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត**» និង«**បច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងស្តង់ដាគុណភាពទឹកស្អាត**» ជូនដល់អាជ្ញាធរ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងប្រជាពលរដ្ឋ បានចំនួន ២វគ្គដូចខាងក្រោម៖

១. ថ្ងៃទី១៥ និង១៦ ខែ មិថុនា ឆ្នាំ២០២៣ រៀបចំនៅសាលាស្រុកកំពង់ត្រាច ខេត្តកំពត។ មានអ្នកចូលរួមសរុបចំនួន ២៥នាក់(ស្រី ៤នាក់)។

២. ថ្ងៃទី១៥ខែ សីហា ឆ្នាំ២០២៣ រៀបចំនៅសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ។ មានអ្នកចូលរួមសរុបចំនួន ២២ នាក់(ស្រី ១នាក់)។




*រូបភាពទី៥៨៖ តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹក*

### *ខ. វគ្គបណ្តុះបណ្តាលគ្រូបង្គោល*

គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការដឹកនាំការផ្សព្វផ្សាយសហគមន៍ឱ្យយល់អំពី«**សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ វិធីសាស្ត្រក្នុងការបន្សុតទឹក និងការទុកដាក់ទឹកឱ្យមានសុវត្ថិភាព**» ជូនដល់អាជ្ញាធរ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ ជាលទ្ធផល វគ្គបណ្តុះបណ្តាលរៀបចំបានចំនួន ១០វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៣៦៦នាក់(ស្រី ៦៤នាក់)។



*រូបភាពទី៥៩៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល*

### គ. ការគាំទ្រការផ្សព្វផ្សាយសហគមន៍

គម្រោងបានរៀបចំគាំទ្រការផ្សព្វផ្សាយសហគមន៍ឱ្យយល់អំពី«**សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់ វិធីសាស្រ្តក្នុងការបន្សុតទឹក និងការទុកដាក់ទឹកឱ្យមានសុវត្ថិភាព**»។ ជាលទ្ធផលគម្រោងគាំទ្រកិច្ចប្រជុំរៀបចំផ្សព្វផ្សាយសហគមន៍បានចំនួន ១៤ប្រជុំ ជូនដល់ ៤៤ឃុំ និង ៣សង្កាត់។ អ្នកចូលរួមសរុបចំនួន ៤៦១នាក់(ស្រី ៥៥នាក់)។



*រូបភាពទី៦០៖ សកម្មភាពគាំទ្រការផ្សព្វផ្សាយសហគមន៍*

## ៨.៦.៥ សិក្ខាសាលាផ្សព្វផ្សាយ «ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងកិច្ចប្រជុំបច្ចេកទេសទឹកស្អាត»

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត រៀបចំសិក្ខាសាលាផ្សព្វផ្សាយ«**ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងកិច្ចប្រជុំបច្ចេកទេសទឹកស្អាត**» នៅភោជនីយដ្ឋានទន្លេបាសាក់២។ អ្នកចូលរួមសរុបចំនួន ២៧នាក់(ស្រី ២នាក់) អញ្ជើញមកពីក្រសួង ឧរបន តំណាងរដ្ឋបាលខេត្តកែប កំពត ព្រះសីហនុ កោះកុង និងរដ្ឋបាលស្រុកទាំង១០ នៃខេត្តតាមតំបន់ជាប់ឆ្នេរសមុទ្រ និងតំណាងអង្គការ AEA។ សិក្ខាសាលានេះមានគោលបំណង ឱ្យភាគីពាក់ព័ន្ធនានា និងអាជ្ញាធរថ្នាក់ក្រោមជាតិយល់កាន់តែច្បាស់អំពីខ្លឹមសារនៃច្បាប់គ្រប់គ្រងទឹកស្អាត ជាពិសេស សិទ្ធិនិងកាតព្វកិច្ចរបស់ប្រតិបត្តិករ និងអាជ្ញាធរ លើការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត ក៏ដូចជាការគាំទ្រស្វែងរកដំណោះស្រាយពីបញ្ហាផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី៦១៖ សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងកិច្ចប្រជុំបច្ចេកទេសទឹកស្អាត*




*រូបភាពទី៦២៖ សិក្ខាសាលាផ្សព្វផ្សាយ ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងកិច្ចប្រជុំបច្ចេកទេសទឹកស្អាត*

## ៨.៦.៦ សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង

ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ សមាគមបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង«**សមត្ថភាពដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED)**» នៅភោជនីយដ្ឋានទន្លេបាសាក់២ មានអ្នកចូលរួមសរុប ៣៤នាក់(ស្រី ៤នាក់) អញ្ជើញមកពីក្រសួង ឧរបន តំណាងរដ្ឋបាលខេត្តកែប កំពត ព្រះសីហនុ កោះកុង និងរដ្ឋបាលស្រុកទាំង១០ នៃខេត្តតាមតំបន់ជាប់ឆ្នេរសមុទ្រ និងមន្ត្រីអង្គការ AEA។ សិក្ខាសាលាឆ្លុះបញ្ចាំងបានពិនិត្យមើលពី៖ ១)លទ្ធផលរបស់គម្រោង ២)បញ្ហាប្រឈមនានា ដំណោះស្រាយ និងមេរៀនរៀនសូត្រ ៣)កំណត់ផែនការសកម្មភាពបន្តក្រោយគម្រោងត្រូវបានបញ្ចប់ និង៤)សំណូមពរ។



*រូបភាពទី៦៣៖ កិច្ចពិភាក្សាតាមខេត្តគោលដៅទាំងបួន ក្នុងកំឡុងសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង*

### ៨.៦.៧ ការបោះពុម្ពសម្ភារៈផ្សព្វផ្សាយ

គម្រោងបានបោះពុម្ពសម្ភារៈអប់រំមួយចំនួន និងបានចែកជូនក្រុមប្រឹក្សាឃុំទាំង៤៧ឃុំ/សង្កាត់ និងប្រតិបត្តិករចំនួន ១២ស្ថានីយដែលនៅក្នុងខេត្តគោលដៅរបស់គម្រោង។ សម្ភារៈមានដូចជា៖ ១)ផ្ទាំងរូបភាពទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ២)សៀវភៅចំណេះដឹងទូទៅ ៣)ផ្ទាំងរូបភាពផ្សព្វផ្សាយសារៈប្រយោជន៍ និងគុណវិប្បត្តិនៃការប្រើប្រាស់ទឹកមិនស្អាត ៤)ផ្ទាំងរូបភាពចំណុះទឹកមួយម៉ែត្រគូប ៥)ផ្ទាំងរូបភាពបម្រែបម្រួលអាកាសធាតុ ៦)ផ្ទាំងរូបភាពការទុកដាក់ទឹកឱ្យមានសុវត្ថិភាព ៧)ផ្ទាំងរូបភាពនៃដំណើរការផលិតទឹកស្អាត និង ៨) ផ្ទាំងរូបភាពបច្ចេកទេសក្នុងការបន្សុតទឹកតាមខ្នងផ្ទះ។

## ៨.៧ គម្រោងសហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកប ដោយបរិយាប័ន្ន ( EMW )

### ៨.៧.១ ការតេស្តសាកល្បងប្រើប្រាស់សម្ភារៈផ្សព្វផ្សាយ

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ក្រោមការឧបត្ថម្ភធនអង្គការ EMW បុគ្គលិកសមាគមបានចូលរួមក្នុងការសាកល្បងប្រើប្រាស់សម្ភារៈផ្សព្វផ្សាយគម្រោង (CLICR-WASH) និងការទទួលបានព័ត៌មានត្រឡប់ពីការផ្សព្វផ្សាយនេះធ្វើឡើងចំនួន ២លើក៖

១. នៅភូមិពុទ្ធវង្ស ឃុំថ្កូវ ស្រុកកំពង់ត្របែក (វគ្គពេលព្រឹក) - ជាឃុំដែលគ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អ្នកចូលរួមជាសហគមន៍ចំនួន ២៦នាក់។

២. នៅភូមិស្វាយទាប ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល (វគ្គពេលរសៀល) - ឃុំដែលមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អ្នកចូលរួមជាសហគមន៍ចំនួន ២៨នាក់។




*រូបភាពទី៦៤៖ ការផ្សព្វផ្សាយការសាកល្បងប្រើប្រាស់សម្ភារជូនដល់សហគមន៍*

### ៨.៧.២ វគ្គបណ្តុះបណ្តាល

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញជូនដល់ប្រតិបត្តិករដែលជាស្ត្រីអ្នកដឹកនាំក្នុងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ វគ្គនេះមានអ្នកចូលរួមសរុបចំនួន ២១នាក់(ស្រី ៥នាក់) ដែលជា

បុគ្គលិក និងម្ចាស់ស្ថានីយចំនួន ១០នាក់ ដែលមកពី ៥ស្ថានីយ មន្ត្រីអង្គការ EMW ៥នាក់ មន្ត្រីអង្គការ DPO ១នាក់ មន្ត្រីអង្គការ CDRI ១នាក់ និងបុគ្គលិកសមាគម ៤នាក់។ វគ្គបណ្តុះបណ្តាលផ្តោតលើប្រធានបទ៖ ១)តួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ២)ស្តង់ដាគុណភាពទឹកស្អាត ៣)យុទ្ធសាស្ត្រទីផ្សារបង្កើនតំណ និងការងារសង្គម ៤)មូលដ្ឋានគ្រឹះនៃគណនេយ្យ និងការកត់ត្រាចំណូលចំណាយ។



*រូបភាពទី៦៥៖ ការថតរូបអនុស្សាវរីយ៍ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល*

## ៨.៧.៣ សិក្ខាសាលា

ថ្ងៃទី១២-១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រោមការឧបត្ថម្ភពីអង្គការ EMW បុគ្គលិកសមាគមចំនួន ២នាក់ (ស្រី ១នាក់) បានចូលរួមក្នុងសិក្ខាសាលាស្តីពីឧបករណ៍វាយតម្លៃដោយខ្លួនឯងលើសមភាពយេនឌ័រ ពិការភាព និងបរិយាប័ន្ន នៅរាជធានីភ្នំពេញ។ សមាសភាពអ្នកចូលរួមអញ្ជើញមកពីប្រទេស កម្ពុជា ឡាវ និងវៀតណាម ចំណែកឯអ្នកសម្របសម្រួលអញ្ជើញមកពីប្រទេសអូស្ត្រាលី និងឥណ្ឌា។



*រូបភាពទី៦៦៖ ការថតរូបអនុស្សាវរីយ៍ក្នុងសិក្ខាសាលា*

## ៨.៨ គម្រោង «ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយ បរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា» ( UTS )

### ៨.៨.១ វគ្គបណ្តុះបណ្តាល

តាមរយៈការឧបត្ថម្ភពីសកលវិទ្យាល័យបច្ចេកវិទ្យាទីក្រុងស៊ីដនី University of Technology Sydney (UTS) សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលចំនួនពីរដូចខាងក្រោម៖

១. ថ្ងៃទី២៤-២៥ ខែសីហា ឆ្នាំ២០២៣ សមាគមបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពី«ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត»។ វគ្គនេះមានគោលបំណង ដើម្បីឱ្យប្រតិបត្តិករត្រៀមខ្លួនរៀបចំឱ្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមានភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជនប្រកបដោយគុណភាព សុវត្ថិភាព និងនិរន្តភាព។ អ្នកចូលរួមសរុបចំនួន ២១នាក់(ស្រី ៦នាក់) មកពី៖ មន្ត្រីរដ្ឋបាលស្រុក ឃុំ ភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលកំពុងផ្គត់ផ្គង់ទឹកស្អាត តំណាងអង្គការជនពិការនៅក្នុងស្រុកសាមគ្គីមានជ័យ។



*រូបភាពទី៦៧៖ វគ្គបណ្តុះបណ្តាលផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត*

២. ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ សមាគមបានផ្តល់វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពី«វិធានការកាត់បន្ថយផលប៉ះពាល់អំពីគ្រោះទឹកជំនន់ និងកាត់បន្ថយផលប៉ះពាល់អំពីគ្រោះរាំងស្ងួតសម្រាប់ការផ្តល់សេវាកម្មទឹកស្អាត» នៅសាលប្រជុំសាលាស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ វគ្គនេះមានគោលបំណងដើម្បីឆ្លុះបញ្ចាំងពីការរៀបចំធ្វើផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ជាពិសេសការកាត់បន្ថយហានិភ័យនិងផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតព្រមទាំងការរៀបចំរបាយការណ៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុផងដែរ។ អ្នកចូលរួមសរុបចំនួន ២៣នាក់(ស្រី ៨នាក់) មកពីមន្ត្រីរដ្ឋបាលស្រុក ឃុំ ភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងអង្គការជនពិការនៅក្នុងស្រុកសាមគ្គីមានជ័យ តំណាងអង្គការ WaterAid និងតំណាងអង្គការ CDRI។




*រូបភាពទី៦៨៖ វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ នៅស្រុកសាមគ្គីមានជ័យ*

## ៩. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ២០២៣ ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុបានសម្រេចលទ្ធផលសំខាន់ដូចខាងក្រោម៖

១. ដំឡើងប្រព័ន្ធគ្រប់គ្រងគណនេយ្យថ្មី (New QuickBooks System) និងរៀបចំគោលការណ៍គណនេយ្យសម្រាប់កម្មវិធី QuickBooks

២. ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ២០២២ និង២០២៣

៣. ជ្រើសរើសប្រើប្រាស់ប្រព័ន្ធអ៊ីធឺណែតប៊ែងឃីង(Internet Banking) សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុសមាគមតាមរយៈធនាគារ។

នៅក្នុងឆ្នាំ២០២៣ ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុបានរៀបចំឯកសារ និងស្វែងរកក្រុមហ៊ុន **វី ឆាធើរ អឺខោនថិន ខូអិលធីឌី** (V Chartered Accountants Co., Ltd) ជាក្រុមហ៊ុនជំនាញ និងឯករាជ្យក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ២០២២ និង២០២៣។ ខាងក្រោមជារបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣៖

| **ចំណូល** | **2023** | **2022** |
|---|---|---|
| ១. មូលនិធីម្ចាស់ជំនួយ | $265,336 | $469,038 |
| ២. សេវាកម្មផ្សេងៗ | $131,517 | $231,959 |
| ៣. វិភាគទានសមាជិកភាព | $78,328 | $60,485 |
| ៤. ចំណូលផ្សេងៗ | $319,649 | $19,574 |
| **ចំណូលសរុប** | **$794,830** | **$781,056** |

| ចំណាយ | 2023 | 2022 |
|---|---|---|
| ១. ចំណាយបុគ្គលិក | $148,398 | $160,781 |
| ២. ចំណាយសកម្មភាព | $500,582 | $387,394 |
| ៣. ចំណាយប្រតិបត្តិការ | $49,398 | $87,250 |
| **ចំណាយសរុប** | **$698,378** | **$635,425** |
| **សមតុល្យចុងឆ្នាំ** | **$96,452** | **$145,631** |

# ១០. បញ្ហាប្រឈម

ក្នុងឆ្នាំ២០២៣ សមាគមបានជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោមៈ

## ១០.១ បញ្ហាប្រឈមរបស់វិស័យទឹកស្អាត

- អ្នកជំនាញលើវិស័យទឹកស្អាតនៅមានកម្រិត
- កំណើននៃការទទួលបានទឹកស្អាតនៅមានកម្រិតទាប
- ការផ្សព្វផ្សាយច្បាប់ និងប្រកាសនៅមានកម្រិត
- ការវិនិយោគលើវិស័យទឹកស្អាតនៅមានកម្រិត
- សកម្មភាពបំពុលទឹក និងបម្រែបម្រួលអាកាសធាតុមានការកើនឡើង
- តំបន់ដែលមិនទាន់មានអាជ្ញាបណ្ណជាតំបន់គ្មានសក្តានុពលក្នុងការទាក់ទាញអ្នកវិនិយោគ
- តំបន់ខ្លះក្នុងអាជ្ញាបណ្ណមិនមានសក្តានុពលក្នុងការវិនិយោគ (មិនអាចធ្វើបាន)
- តំបន់ខ្លះទទួលរងគ្រោះទឹកជំនន់ និងខ្លះរាំងស្ងួត
- ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតនៅមានកម្រិត

## ១០.២ បញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

- ខូចខាតបំពង់ទឹកស្អាតដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ដោយគ្មានសំណង)
- ខ្វះទុនវិនិយោគ(ការពង្រីកបំពង់ទឹកស្អាត និងរោងចក្រផលិតទឹកស្អាត)
- មិនទាន់ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល
- មិនទាន់ទទួលបានការគាំទ្រពីអាជ្ញាធរមូលដ្ឋានពេញលេញ
- ប្រតិបត្តិករមិនអាចឆ្លើយតបទៅនឹងតម្រូវការធនាគារ/មីក្រូហិរញ្ញវត្ថុ
- ចំណេះដឹងរបស់ប្រតិបត្តិករលើផ្នែកបច្ចេកទេស និងការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត
- ការផ្សព្វផ្សាយដើម្បីឱ្យប្រជាពលរដ្ឋយល់អំពីគុណប្រយោជន៍ទឹកស្អាតនៅមានកម្រិត
- គុណភាពសេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករមួយចំនួននៅមានកម្រិត
- ប្រតិបត្តិករមួយចំនួនខ្វះខាតប្រភពទឹក
- ចំណេះដឹងរបស់ប្រតិបត្តិករអំពីពន្ធដារនៅមានកម្រិត
- ប្រតិបត្តិករភាគច្រើនជាលក្ខណៈអាជីវកម្មបែបគ្រួសារ

## ១០.៣ បញ្ហាប្រឈមរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

- ❖ មានទំនួលខុសត្រូវច្រើន
- ❖ ធនធានមានកម្រិត (ថវិកា និងមនុស្ស)
- ❖ សមាជិកខ្លះមិនមានឆន្ទៈក្នុងការបង់ប្រាក់វិភាគទានប្រចាំឆ្នាំ
- ❖ ប្រតិបត្តិករខ្លះដែលទទួលបានប្រកាសអនុញ្ញាត(អាជ្ញាបណ្ណ)មិនមានឆន្ទៈចូលជាសមាជិកសមាគម។
- ❖ សមាគមអាចកសាងសមត្ថភាពជូនប្រតិបត្តិករ ប៉ុន្តែប្រតិបត្តិករមួយចំនួនមិនមានឆន្ទៈក្នុងការកសាងសមត្ថភាពរបស់ខ្លួន។

# ១១. សមាសភាពក្រុមប្រឹក្សាភិបាលសមាគម និងបុគ្គលិក

## ១១.១. ក្រុមប្រឹក្សាភិបាលសមាគម

ក្រុមប្រឹក្សាភិបាលអាណត្តិទី៣ សម្រាប់ឆ្នាំ២០២០-២០២៣ មានចំនួន ៩នាក់ (ស្រី ១នាក់) ដូចមានរាយនាមក្នុងអង្គការលេខដូចខាងក្រោមៈ



**លោក ឡេង ឌៀវ**
ប្រធានក្រុមប្រឹក្សាភិបាល

**លោក ឡេង ឌៀវ** ជាប្រធានក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកជាប្រធានសមាគម និងជាតំណាងស្របច្បាប់របស់សមាគមដែលមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវរាល់សកម្មភាពរបស់សមាគម។ ក្នុងអាណត្តិនេះ លោកបានដឹកនាំការងារសំខាន់ៗរបស់សមាគមឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយសមាជិកឱ្យមានភាពរីកចម្រើនក្នុងអាជីវកម្ម ជាពិសេសប្រតិបត្តិករដែលមិនមានលទ្ធភាព និងចង់ឃើញប្រជាពលរដ្ឋទូទាំងប្រទេសមានទឹកស្អាតប្រើប្រាស់គ្រប់ៗគ្នា។

**លោក ឡេង ឌៀវ** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១៨ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ឌៀវ ព្រែកអំបិល ដែលស្ថិតនៅស្រុកស្អាង ខេត្តកណ្តាល និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតល្វារំចេក ដែលស្ថិតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង។



**លោក ហម ងួន**
អនុប្រធានក្រុមប្រឹក្សាភិបាល

**លោក ហម ងួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី២ (២០១៦-២០១៩)។ លោកជាអនុប្រធានសមាគម និងជាសេនាធិការឱ្យប្រធានសមាគម និងមានតួនាទីជំនួសប្រធាននៅពេលប្រធានអវត្តមានក្នុងឋានៈជាប្រធានស្តីទី។ ក្នុងពីរអណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មក្នុងការដឹកនាំសមាគមឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយសមាជិកសមាគមឱ្យមានភាពរីកចម្រើនក្នុងអាជីវកម្ម តាមលទ្ធភាពដែលខ្លួនមាន។

**លោក ហម ងួន** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ២០ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង ដែលស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងស្ថានីយទឹកផ្គត់ផ្គង់ស្អាតតេជោមានជ័យ ដែលស្ថិតនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។



**លោក សៀ សេងហ៊ាប**
ហេរញ្ញិកក្រុមប្រឹក្សាភិបាល

**លោក សៀ សេងហ៊ាប** ជាហេរញ្ញិកនៃក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣(២០២០-២០២៣)។ លោកធ្លាប់ជាអនុប្រធានសមាគមនៅអាណត្តិទី២ (២០១៦-២០១៩)។ លោកមានតួនាទីជាអ្នកជានាឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់សមាគមមានគណនេយ្យភាព តម្លាភាព និងសុចរិតភាព។ លោកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូលចំណាយរបស់សមាគម សហការក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ និងបំពេញការងារមួយចំនួនទៀតតាមការចាត់ចែងរបស់ប្រធាន។ ក្នុងពីរអាណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មជាមួយប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ដើម្បីសម្រេចឱ្យបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយពង្រឹងសមាគមឱ្យមានភាពរឹងមាំ តាមរយៈការស្វែងរកដៃគូអភិវឌ្ឍន៍ និងដៃគូដែលផ្តល់កម្ចីមានរយៈពេលវែងជូនដល់សមាជិក ពង្រឹងសមាគមក្នុងការតស៊ូមតិ និងពង្រឹងសាមគ្គីភាពក្នុងវិស័យទឹកស្អាត។

**លោក សៀ សេងហ៊ាប** មានបទពិសោធន៍លើវិស័យទឹកស្អាតជិត ២០ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បែកចាន ដែលស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល។



**លោកស្រី យ៉ាន ធីតា**
សមាជិកក្រុមប្រឹក្សាភិបាល

**អ្នកស្រី យ៉ាន ធីតា** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ អ្នកស្រីមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាល ក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ អ្នកស្រីទទួលបន្ទុកការងារផ្សេងៗទៀត តាមការបែកចែកដោយប្រធានក្រុមប្រឹក្សាភិបាល។ ក្នុងអាណត្តិនេះ អ្នកស្រី បានចូលរួមយ៉ាងសកម្មក្នុងការងាររបស់ក្រុមប្រឹក្សាភិបាលដើម្បីឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ អ្នកស្រីមានទស្សនវិស័យចង់ជួយសមាគមឱ្យកាន់តែរីកចម្រើន និងបានចែករំលែកបទពិសោធន៍ល្អ ដើម្បីលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។

**អ្នកស្រី យ៉ាន ធីតា** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១០ឆ្នាំ។ អ្នកស្រី ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម ដែលស្ថិតនៅស្រុកសូទ្រនិគម ខេត្តសៀមរាប។



**លោក ចាន់ ថានី**
សមាជិកក្រុមប្រឹក្សាភិបាល

**លោក ចាន់ ថានី** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ លោកទទួលបន្ទុកការងារផ្សេងៗទៀតតាមការបែកចែកដោយប្រធាន។ ក្នុងអាណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយសមាគមឱ្យកាន់តែរីកចម្រើន។

**លោក ចាន់ ថានី** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១៤ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបរហ៊ុយ ដែលស្ថិតនៅក្រុងប៉ៃលិន ខេត្តប៉ៃលិន។



**លោក ហៀក អេងឡាយ**
សមាជិកក្រុមប្រឹក្សាភិបាល

**លោក ហៀក អេងឡាយ** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ លោកទទួលបន្ទុកការងារផ្សេងៗទៀត តាមការបែកចែកដោយប្រធាន។ ក្នុងអាណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីឱ្យសម្រេចបានតាម ចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ពង្រឹងសាមគ្គីភាពលើវិស័យទឹកស្អាត។

**លោក ហៀក អេងឡាយ** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១១ ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ ដែលស្ថិតនៅស្រុកកំចាយមារ ខេត្តព្រៃវែង។



**លោក ជា សំបូរ**
សមាជិកក្រុមប្រឹក្សាភិបាល

**លោក ជា សំបូរ** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ លោកទទួលបន្ទុកការងារផ្សេងៗទៀត តាមការបែកចែកដោយប្រធាន។ ក្នុងអាណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយលើកកម្ពស់វិស័យទឹកស្អាត។

**លោក ជា សំបូរ** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១៦ឆ្នាំ។ លោកជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតផ្សារអង្គតាសោម ដែលស្ថិតនៅស្រុកត្រាំកក់ ខេត្តតាកែវ និងស្ថានីយទឹកស្អាតក្រូចឆ្មារ ដែលស្ថិតនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។



**លោក សៀវ ហួត**
សមាជិកក្រុមប្រឹក្សាភិបាល

**លោក សៀវ ហួត** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ លោកទទួលបន្ទុកការងារផ្សេងៗទៀតតាមការបែកចែកដោយប្រធាន។ ក្នុងអាណត្តិនេះ លោកបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្ររបស់សមាគម។ លោកមានទស្សនវិស័យចង់ជួយលើកកម្ពស់វិស័យទឹកស្អាត ។

**លោក សៀវ ហួត** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១៦ឆ្នាំ។ លោកជាអ្នកគ្រប់គ្រងស្ថានីយផ្គត់ផ្គង់ទឹកស្អាតអ្នកលឿង ស្ថិតនៅស្រុកពាមរក៍ ខេត្តព្រៃវែង ស្ថានីយផលិតទឹកស្អាតស្វាយរមៀត ឯ.ក ស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងស្ថានីយទឹកស្អាតមេសរជ្រៃ-សូភាស ស្ថិតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។



**លោក លាង បញ្ញា**
សមាជិកក្រុមប្រឹក្សាភិបាល

**លោក លាង បញ្ញា** ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី៣ (២០២០-២០២៣)។ លោកមានតួនាទីសហការជាមួយប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំសមាគម និងចូលរួមធ្វើសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាភិបាល។ លោកទទួលបន្ទុកការងារផ្សេងៗទៀតតាមការបែកចែកដោយប្រធាន។ ក្នុងអាណត្តិនេះលោកបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីឱ្យសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ។ លោកមានទស្សនវិស័យចង់ជួយផ្តល់ចំណេះដឹងបច្ចេកទេស និងចំណេះដឹងថ្មីៗជូនសមាជិក និងជួយដោះស្រាយបញ្ហារបស់សមាគម។

**លោក លាង បញ្ញា** មានបទពិសោធន៍លើវិស័យទឹកស្អាតជាង ១៥ឆ្នាំ។ លោក ជាអ្នកគ្រប់គ្រងទូទៅនៃស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកតាមាក់ ដែលស្ថិតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

## ១១.២. បុគ្គលិកសមាគម

បច្ចុប្បន្នសមាគមមានបុគ្គលិកចំនួន ៩នាក់ (ស្រី ៤នាក់) ដែលមានឈ្មោះ និងតួនាទីដូចខាងក្រោម៖



**លោក លឹម មិញ**
នាយកប្រតិបត្តិ

**លោក លឹម មិញ** នាយកប្រតិបត្តិសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ លោកបានចាប់ផ្តើមការងារជាមួយសមាគមនៅចុងឆ្នាំ២០១៧។ លោកជាអ្នកគ្រប់គ្រងទូទៅរបស់សមាគម និងទទួលខុសត្រូវលើការងារប្រតិបត្តិការរបស់សមាគមទាំងផ្នែកកម្មវិធី និងហិរញ្ញវត្ថុ។ លោកជាអ្នកធ្វើការសម្រេចចិត្តសំខាន់បំផុតក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីជានាសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម របស់សមាគម។

**លោក លឹម មិញ** មានបទពិសោធន៍ការងារជាង២០ឆ្នាំ ក្នុងវិស័យអប់រំ អភិវឌ្ឍន៍សហគមន៍ ទឹកស្អាត និងអនាម័យ និងការគ្រប់គ្រងគម្រោងកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។ គាត់ធ្លាប់បានបំពេញការងារជាមួយ អង្គការទស្សនពិភពលោកកម្ពុជា (WVC) អង្គការសង្គ្រោះកុមារអូស្ត្រាលី (SCA) អង្គការអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់(GIZ) អង្គការអេអេដអាកស្យុង (AEA)។ លោកបានបញ្ចប់បរិញ្ញាប័ត្រវិទ្យាសាស្ត្រគណិតវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សញ្ញាប័ត្រគ្រូមធ្យមសិក្សាកម្រិត២ មុខវិជ្ជាឯកទេស គណិតវិទ្យា ពីមហាវិទ្យាល័យគរុកោសល្យ និងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងគម្រោង និងអភិវឌ្ឍន៍ជនបទ ពីសាកលវិទ្យាល័យបៀលប្រាយ។

---



**លោក ហុង គឹមលី**
ប្រធានផ្នែកទំនាក់ទំនង

**លោក ហុង គឹមលី** ប្រធានផ្នែកទំនាក់ទំនងនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ លោកចាប់ផ្តើមចូលបម្រើការងារជាមួយសមាគម នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។ លោកទទួលខុសត្រូវលើការងារស្នូលរបស់សមាគម សម្របសម្រួលសមាជិកភាព ទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ សមាជិកសមាគម និងអាជ្ញាធរពាក់ពន្ធនានាក្នុងវិស័យទឹកស្អាត។

**លោក ហុង គឹមលី** មានបទពិសោធន៍ការងារជាង ៣០ឆ្នាំក្នុងវិស័យអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងគម្រោងកម្មវិធីនៅក្នុងប្រទេសកម្ពុជា។ គាត់ធ្លាប់បានបំពេញការងារជាមួយអង្គការ ស៊ីដសេ (CIDSE) និង ឌីភីអេ (DPA) ក្នុងតួនាទីជាប្រធានគម្រោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះ។ គម្រោងនេះផ្តោតទៅលើផ្នែកសុខភាព និងអនាម័យ កសិកម្ម ការអប់រំ និងការគ្រប់គ្រងធនធានធម្មជាតិ។ **លោក ហុង គឹមលី** ក៏ជាទីប្រឹក្សាជាន់ខ្ពស់របស់អង្គការ វីប៊ីអិនខេ (VBNK) ក្នុងការផ្តល់ការអភិវឌ្ឍន៍សមត្ថភាពដល់អង្គការដៃគូ និងសហជីព/សហព័ន្ធ លើផ្នែកការអភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងភាពជាអ្នកដឹកនាំ។ លោកបានបញ្ចប់បរិញ្ញាប័ត្រ ផ្នែកវារីសាស្ត្រកសិកម្ម ពីវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត និងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យបៀលប្រាយ។



**កញ្ញា ស៊ឹម បូនិច**

ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

**កញ្ញា ស៊ឹម បូនិច** ជាប្រធានរដ្ឋបាល និងហិរញ្ញវត្ថុនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កញ្ញាចាប់ផ្ដើមចូលបម្រើការងារជាមួយសមាគម នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣។ កញ្ញាទទួលខុសត្រូវការងារ ការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ ការគ្រប់គ្រងថវិកា ការធ្វើរបាយការណ៍ ការអភិវឌ្ឍន៍លើការត្រួតពិនិត្យ និងតាមដានលើគោលនយោបាយជាមួយចំណាយជាក់ស្ដែង ផ្ដល់ការហ្វឹកហាត់ និងផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមការងារ និងភាគីពាក់ព័ន្ធលើការគ្រប់គ្រងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត កញ្ញាទទួលខុសត្រូវលើការសម្របសម្រួលតាមម្ចាស់ជំនួយ សវនកម្ម និងឆ្លើយតបតាមតម្រូវការរបស់រាជរដ្ឋាភិបាល ព្រមទាំងកិច្ចការងារផ្សេងៗដើម្បីសម្រេចឱ្យបាននូវការអនុវត្តស្របតាមអភិបាលកិច្ចល្អរបស់ស្ថាប័ន។

**កញ្ញា ស៊ឹម បូនិច** បានបញ្ចប់បរិញ្ញាបត្រ គណនេយ្យ នៅវិទ្យាស្ថានវ៉ាន់ដា។ បច្ចុប្បន្ន កញ្ញាបានកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និងសវនកម្ម នៅវិទ្យាស្ថានវ៉ាន់ដា។ កញ្ញាមានបទពិសោធន៍ការងារផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រតិបត្តិការ ជាង ១២ឆ្នាំជាមួយអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ព្រមទាំងធនាគារ។

ការវិវត្តការងាររបស់ **កញ្ញា ស៊ឹម បូនិច** ចាប់ពីកម្រិតទាបរហូតដល់ កម្រិតថ្នាក់គ្រប់គ្រង នេះដោយសារតែសមត្ថភាពក្នុងការរៀនសូត្របានយ៉ាងឆាប់រហ័សរបស់កញ្ញា។



**លោកស្រី ដួក ម៉ារី**

មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

**អ្នកស្រី ដួក ម៉ារី** ជាតួនាទីមន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុនៃសមាគមផ្គង់ផ្គត់ទឹកស្អាតកម្ពុជា។ អ្នកស្រីបានចាប់ផ្ដើមបម្រើការងារជាមួយសមាគមចំនួនពីរលើក លើកទី១ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ និងលើកទី២ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។ បច្ចុប្បន្ននេះ អ្នកស្រីទទួលខុសត្រូវសំខាន់ៗរួមមាន៖ ការរៀបចំបញ្ជីបើកប្រាក់ខែបុគ្គលិក ពិនិត្យមើលរាល់ឯកសារចំណាយ និងប្រតិបត្តិការគណនេយ្យឱ្យបានត្រឹមត្រូវមុននឹងបញ្ចូលក្នុងប្រព័ន្ធគណនេយ្យ (QuickBooks) ធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងការទូទាត់ការរៀបចំឯកសារសម្រាប់បេឡាជាតិរបបសន្តិសុខសង្គមនិងការបង់ពន្ធប្រចាំខែ។ អ្នកស្រីក៏ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនិងគ្រប់គ្រងផ្នែករដ្ឋបាលដើម្បីសម្រេចបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និងអនុលោមតាមគោលនយោបាយរបស់សមាគម និងគោរពតាមបទបញ្ជារបស់រដ្ឋាភិបាល។

**អ្នកស្រី ដួក ម៉ារី** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបៀលប្រាយក្នុងឆ្នាំ២០១៦។ អ្នកស្រីមានបទពិសោធន៍ការងារផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ជាង ៨ឆ្នាំជាមួយអង្គការមិនមែនរដ្ឋាភិបាល។



**អ្នកស្រី តូច សុគន្ធា**
អ្នកសម្របសម្រួលកម្មវិធី

**អ្នកស្រី តូច សុគន្ធា** មានតួនាទីជាអ្នកសម្របសម្រួលកម្មវិធីនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ អ្នកស្រីបានចាប់ផ្ដើមបម្រើការងារជាមួយសមាគមចំនួនពីរលើក លើកទី១ នៅឆ្នាំ២០១៥ និងលើកទី២ នៅឆ្នាំ២០១៩។ បច្ចុប្បន្ននេះ អ្នកស្រីទទួលខុសត្រូវក្នុងការសម្របសម្រួលគម្រោងរបស់សមាគម និងការផ្ដល់ការកសាងសមត្ថភាពដល់សមាជិកជាប្រតិបត្តិករ និងអ្នកពាក់ព័ន្ធនានា។ អ្នកស្រីក៏ធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រធានគ្រប់គ្រងកម្មវិធី និងនាយកប្រតិបត្តិដើម្បីសរសេរសំណើគម្រោង រៀបចំកម្មវិធី និងសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ ដើម្បីធានាថា គម្រោងសម្រេចបាននូវគោលដៅដែលបានគ្រោងទុក។

**អ្នកស្រី តូច សុគន្ធា** មានបទពិសោធន៍ជាង ២០ ឆ្នាំ ក្នុងវិស័យអប់រំ និងការងារអភិវឌ្ឍន៍ជាមួយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិនៅកម្ពុជា។ អ្នកស្រីធ្លាប់បានបំពេញការងារជាមួយស្ថាប័នរដ្ឋ សមាគមយុវជនខ្មែរ (KYA) អង្គការទស្សនពិភពលោកកម្ពុជា (WVC) អង្គការវិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (VBNK) អង្គការលំនៅដ្ឋានមនុស្សជាតិកម្ពុជា (HHC)។ អ្នកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម (MBA) ជំនាញគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យបៀលប្រាយ។

---



**លោក ជ្រិន ផាត់**
វិស្វករជំនាញជាន់ខ្ពស់ទឹកស្អាត

**លោក ជ្រិន ផាត់** ជាវិស្វករជាន់ខ្ពស់ទឹកស្អាត នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ លោក ចាប់ផ្ដើមបម្រើការងារមួយសមាគមនៅឆ្នាំ២០១៤។ បច្ចុប្បន្ន លោកជាអ្នកឯកទេសក្នុងការរចនាប្រព័ន្ធចែកចាយទឹកតាមបំពង់ សិក្សាសមិទ្ធិលទ្ធភាពវិនិយោគសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អភិវឌ្ឍន៍សមត្ថភាពសមាជិក និងប្រឹក្សាយោបល់លើផ្នែកបច្ចេកទេស និងបទប្បញ្ញត្តិនានា និងផ្ដល់សេវាកម្មផ្នែកបច្ចេកទេសជូនសមាជិក និងដៃគូនានារបស់សមាគម។ ជាងនេះទៅទៀត លោកទទួលខុសត្រូវដឹកនាំ និងសម្របសម្រួលការងារគម្រោងជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ការអភិវឌ្ឍន៍វិស័យទឹកស្អាត ក៏ដូចការសម្រេចនូវគោលបំណងសមាគម ដើម្បីជួយឱ្យប្រជាជនទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត។

**លោក ជ្រិន ផាត់** បានបញ្ចប់ការសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ផ្នែកវិស្វករ ឯកទេស វិស្វកម្មធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធជនបទ នៅឆ្នាំ២០១៤។

---



**កញ្ញា ខាត់ ដាវី**
មន្ត្រីបច្ចេកទេសទឹកស្អាត អនាម័យ
និងសម្របសម្រួល

**កញ្ញា ខាត់ ដាវី** ជាមន្ត្រីបច្ចេកទេសទឹកស្អាត អនាម័យ និងសម្របសម្រួលសមាជិកនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កញ្ញាបានចាប់ផ្ដើមការងារជាមួយសមាគមនៅឆ្នាំ២០១៦ ក្រោយបញ្ចប់ការសិក្សារហូតមកដល់បច្ចុប្បន្ន។ កញ្ញាទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍សមត្ថភាពសមាជិក ប្រឹក្សាយោបល់លើផ្នែកបច្ចេកទេស និងបទប្បញ្ញត្តិនានា ផ្ដល់សេវាកម្មផ្នែកបច្ចេកទេសជូនសមាជិក គ្រប់គ្រងទិន្នន័យសមាជិក ចូលរួមជាមួយថ្នាក់ដឹកនាំសមាគមក្នុងការសម្របសម្រួលបញ្ហារបស់សមាជិក និងរួមចំណែកអនុវត្តគម្រោងនានា។ កញ្ញាក៏ធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានផ្នែកទំនាក់ទំនង និងនាយកប្រតិបត្តិ ដើម្បីធានាឱ្យការងារសម្រេចបានតាមគោលដៅដែលបានគ្រោងទុក។

**កញ្ញា ខាត់ ដាវី** បានបញ្ចប់ការសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ផ្នែកវិស្វករ ឯកទេស វិស្វកម្មធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធជនបទ នៅឆ្នាំ២០១៦។



**លោក ឯម សារ៉ុម**
មន្ត្រីទំនាក់ទំនង

**លោក ឯម សារ៉ុម** ជាមន្ត្រីទំនាក់ទំនងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ លោកបានចាប់ផ្តើមបម្រើការងារជាមួយសមាគមនៅខែសីហា ឆ្នាំ២០១៨។ លោកទទួលខុសត្រូវទៅលើការរចនារូបភាពអប់រំ សម្របសម្រួល និងថតវីដេអូផ្សព្វផ្សាយ រៀបចំការបោះពុម្ពនានារបស់សមាគម អភិវឌ្ឍន៍គេហទំព័រសមាគម ព្រមទាំងបណ្តាញទំនាក់ទំនងសង្គម ក៏ដូចជាការគាំទ្រដល់គម្រោងនានាដែលក្រុមការងារត្រូវការ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្ម របស់សមាគម។

**លោក ឯម សារ៉ុម** មានបទពិសោធន៍ការងារ ១០ឆ្នាំ ក្នុងវិស័យអភិវឌ្ឍន៍ និងគាំទ្រសង្គម និងក្នុងវិស័យទឹកស្អាត និងអនាម័យ។ គាត់ធ្លាប់បានបំពេញការងារជាមួយអង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)។ លោកបានបញ្ចប់បរិញ្ញាប័ត្រ ផ្នែកទំនាក់ទំនងអន្តរជាតិពីសាកលវិទ្យាល័យកម្ពុជា (UC)។



**លោក សារ៉ែន ហ៊ិន**
ជំនួយការផ្នែកព័ត៌មានវិទ្យា

**លោក សារ៉ែន ហ៊ិន** ជាជំនួយការផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា។ លោកបានចាប់ផ្តើមបម្រើការងារជាមួយសមាគមនៅឆ្នាំ២០២០ ដែលមានរយៈពេលជាង ៣ឆ្នាំ។ លោកទទួលខុសត្រូវទៅលើការងារដោះស្រាយបញ្ហាខាងបច្ចេកទេស ផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា ផ្នែកខាងរចនាគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គម ជួសជុលសម្ភារៈការិយាល័យ កុំព្យូទ័រ ទូរស័ព្ទ ព្រីនធើ អ៊ិនធើណេត។ល។ លោកបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅឆ្នាំ២០១៥ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) និងបរិញ្ញាបត្ររង ផ្នែកអក្សរសាស្ត្រអង់គ្លេស ឆ្នាំ២០១៦ ពីវិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា (CICI)។

**លោក សារ៉ែន ហ៊ិន** ជាជនជាតិដើមភាគតិចគ្រឹង មកពីខេត្តរតនគិរី និងមានបទពិសោធន៍ការងារផ្នែកជំនាញព័ត៌មានវិទ្យាជាង ៧ឆ្នាំជាមួយក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

**លោក សារ៉ែន ហ៊ិន** ចង់ឃើញសមាគមមានភាពរឹងមាំ កាន់តែរីកចម្រើន ដោយលោកចង់ជួយសមាគមតាមរយៈការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ និងពង្រឹងសាមគ្គីក្នុងក្រុមការងារ ជួយដល់សមាគមក្នុងការលើកកម្ពស់លើវិស័យទឹកស្អាត ដើម្បីសម្រេចបានគោលដៅ និងទស្សនវិស័យរបស់សមាគម។




មជ្ឈមណ្ឌលភ្នំពេញ អគារ F
ជាន់ទី២ បន្ទប់លេខ ២៦៩
វិថីសម្តេចសុធារស

(+៨៥៥) ០១៧ ៧៩៩ ៣៣៧/
០៧០ ៧៩៩ ៣៣៧/
០៩៧ ៧១ ៧៩ ៩៤៣

www.facebook.com/cwa.org.kh
www.cwa.org.kh
info@cwa.org.kh


